

# របាយការណ៍ វេទិកានគរូបនីយកម្ម កម្ពុជា

ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និង បរិយាបន្ន

ថ្ងៃ២៧ ខែវិច្ឆិកា ឆ្នាំ២០១៩| ភ្នំពេញ កម្ពុជា

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
Ministry of Land Management
Urban Planning and Construction

UNITED NATIONS
CAMBODIA



# មាតិកា


| | |
|---|---|
| បុព្វកថា | IV |
| ១. ទិដ្ឋភាពរួមទូទៅ | ១ |
| ១.១. ព័ត៌មានសាវតារ | ១ |
| ១.២. វេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ១ |
| ១.៣. របៀបវារៈនៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ២ |
| ១.៤. ព័ត៌មានសង្ខេបអំពីអ្នកចូលរួមវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ៣ |
| ២. របាយការណ៍សង្ខេបអំពីវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ៤ |
| ២.១. ពិធីបើកវេទិកា | ៤ |
| ២.២. ទិដ្ឋភាពរួមទូទៅអំពីនគរូបនីយកម្ម៖ ស្ថានភាពបញ្ហាប្រឈម និងកាលានុវត្តភាព | ៨ |
| ២.៣. ការកំណត់ពីអាទិភាពទីក្រុងរបស់ប្រទេសកម្ពុជា ៖ ការជំរុញលើកកម្ពស់គោលនយោបាយ និងការសម្រេចឱ្យបាននូវទីក្រុងប្រកបដោយចីរភាព | ១០ |
| ២.៤. ការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង | ១២ |
| ២.៥. សេចក្តីថ្លែងការណ៍របស់យុវជន | ១៤ |
| ២.៦. ជំហានបន្ទាប់ និងកម្មវិធីបិទ | ១៧ |
| ៣. សេចក្តីប្រកាសនៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ២១ |
| ឧបសម្ព័ន្ធទី ១: របៀបវារៈវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ២៥ |
| ឧបសម្ព័ន្ធទី ២: បញ្ជីឈ្មោះអ្នកចូលរួមវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ | ២៨ |
| ឧបសម្ព័ន្ធទី ៣៖ របាយការណ៍នៃកិច្ចប្រជុំមុនវេទិកា | ៣៣ |
| ឧបសម្ព័ន្ធទី ៤: ព្រឹត្តិការណ៍កសាងបណ្តាញកម្រិតខ្ពស់ | ៤៤ |

# បុព្វកថា



ប្រជាជាតិកម្ពុជាទាំងមូលកំពុងរស់នៅក្នុងសុខសន្តិភាព ឯកភាពជាតិនិងទឹកដី ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ តាមរយៈការអនុវត្តនយោបាយ “**ឈ្នះ ឈ្នះ**” និងយុទ្ធសាស្ត្រចតុកោណដែលជារបៀបវារៈនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ប្រជាជនកម្ពុជាបានគាំទ្រជាធ្លុងមួយចំពោះការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលបានធានាសុខសន្តិភាព ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដោយបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការលើកកម្ពស់សិទ្ធិមនុស្ស និងការពង្រឹងនីតិរដ្ឋ ស្តែងឡើងតាមរយៈការបោះឆ្នោតសកលកាលពីខែកក្កដា ឆ្នាំ២០១៨ ដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាពដែលមានប្រជាពលរដ្ឋចូលរួមបោះឆ្នោតដល់ទៅ ៨៣,០២% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គ្រង់ចតុកោណទី៤ បានកំណត់អំពីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន និងការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម តាមរយៈការអភិវឌ្ឍទីក្រុងឱ្យមានបរិស្ថានល្អសម្រាប់ការរស់នៅ គុណភាព សុវត្ថិភាព សោភណភាព សុខុមាលភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច-សង្គម ស្របតាមគោលការណ៍ទីក្រុងឆ្លាតវៃក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្នតាមរយៈការជំរុញការអភិវឌ្ឍ និងការពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្តដោយផ្សារភ្ជាប់យុទ្ធសាស្ត្រសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទីក្រុងជាមួយការអនុវត្តនិងការអភិវឌ្ឍនគរូបនីយកម្ម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានកំណត់ច្បាស់អំពីចក្ខុវិស័យថា “**ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ**” ដោយបានកំណត់យុទ្ធសាស្ត្រតំបន់ប៉ូលអភិវឌ្ឍជាតិ តំបន់ស្នូល និងអ័ក្សនៃការអភិវឌ្ឍជាតិដែលមានសក្តានុពល និងអាទិភាពសម្រាប់ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ព្រមទាំងកិច្ចការពារបរិស្ថាន និងធម្មជាតិប្រកបដោយចីរភាព។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់នូវផែនការរៀបចំដែនដី និងផែនការរូបវន្តទីក្រុងជាច្រើនមានជាអាទិ៍ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តបាត់ដំបង ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង ក្រុងសៀមរាប ក្រុងតាខ្មៅ ក្រុងកំពត ក្រុងកែប ក្រុងខេមរភូមិន្ទ ក្រុងបាវិត ក្រុងប៉ោយប៉ែត ក្រុងស្ទឹងត្រែង គម្រោងអភិវឌ្ឍក្រុងបូកគោ ទីប្រជុំជនជ្រៃធំ ទីប្រជុំជនត្បូងឃ្មុំ ផែនការប្រើប្រាស់ដីឃុំ សង្កាត់ ប្លង់ហេដ្ឋារចនាសម្ព័ន្ធ

ផែនទីព្រំប្រទល់រដ្ឋបាល ផែនទីប្រើប្រាស់ដីគ្រប់រាជធានី ខេត្តដែលបានកំណត់ច្បាស់អំពីចក្ខុវិស័យ យុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងគោលដៅធានាការអភិវឌ្ឍទីក្រុង ការប្រើប្រាស់ដី និងការអភិវឌ្ឍដីឱ្យបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព ធានាបានចីរភាព និងតុល្យភាព។

ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនគរូបនីយកម្ម និងការគ្រប់គ្រងការអភិវឌ្ឍអចលនទ្រព្យនិងសំណង់ ច្បាប់ស្តីពីសំណង់ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ នេះ មានគោលការណ៍សំខាន់គឺការពារផលប្រយោជន៍សាធារណៈ សិទ្ធិបុគ្គល ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន ការរៀបចំដែនដីនិងនគរូបនីយកម្ម ការអភិវឌ្ឍបៃតង ការការពារធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការរក្សា និងលើកកម្ពស់អត្តសញ្ញាណជាតិ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានសហការជាមួយតំណាងការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជារៀបចំជាលើកដំបូង “**វេទិកានគរូបនីយកម្មកម្ពុជាស្តីពីការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន**” ក្នុងគោលបំណងចែករំលែកចំណេះដឹង បទពិសោធន៍នៃការអភិវឌ្ឍ គោលនយោបាយ ចក្ខុវិស័យ យុទ្ធសាស្ត្រ វិស័យអាទិភាព ការពង្រីកទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍដី សហគមន៍ឆ្លាតវៃ បរិយាបន្ន ស្ថានភាពទីក្រុង បញ្ហាប្រឈម ដំណោះស្រាយ និន្នាការ កាលានុវត្តភាព នវានុវត្តន៍ ការសម្របសម្រួល ភាពជាដៃគូ ការផ្តល់ហិរញ្ញប្បទាន ការកសាងសមត្ថភាព ការការពារធនធានធម្មជាតិនិងបរិស្ថាន ការការពារគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមួយតំណាងការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិ។ វេទិកានេះត្រូវបានធ្វើឡើងនៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤ ដែលបានផ្តល់នូវកាលានុវត្តភាពយ៉ាងច្រើនដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជាក្នុងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ពន្លឿនការអភិវឌ្ឍប្រទេសយ៉ាងឆាប់រហ័សតាមរយៈផលិតកម្មផ្អែកលើប្រព័ន្ធឌីជីថលនិងបញ្ញាសិប្បនិម្មិតក្នុងការបង្កើនផលិតភាពប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព និងភាពប្រកួតប្រជែង។

ជាលទ្ធផល អង្គវេទិកាបានទទួលស្គាល់ថា "**អភិក្រមនគរូបនីយកម្ម**" នឹងកាន់តែមានប្រសិទ្ធភាពតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ ការជំរុញការចូលរួមគាំទ្រ ការពង្រឹងចំណេះដឹង ការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដី គោលនយោបាយជាតិស្តីពីលំនៅឋាន និងការស្វែងរកដំណោះស្រាយរួមគ្នាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីបង្កើតភាពជាដៃគូដោយផ្តោតលើការអនុវត្តសកម្មភាពជាក់ស្តែងនៅគ្រប់កម្រិតទាំងអស់។ ទន្ទឹមជាមួយគ្នានេះ វេទិកានគរូបនីយកម្មកម្ពុជាលើកទី១ ពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍទីក្រុងនាពេលអនាគតដោយយកចិត្តទុកដាក់លើតម្រូវការនិងការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានដល់ទីក្រុង និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋដើម្បីសម្រេចឱ្យបាននូវវិបុលភាពរយៈពេលវែងនៅព្រះរាជាណាចក្រកម្ពុជា។ វេទិកានេះ ពិតជាមានសារៈសំខាន់ផងដែរក្នុងការជំរុញឱ្យទីក្រុងរបស់កម្ពុជាក្លាយជាតំបន់ស្នូលនៃកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និង

ចីរភាពសំដៅធានាបាននូវម៉ាក្រូសេដ្ឋកិច្ចរឹងមាំបន្តទៀត និងឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ខ្ញុំសូមគាំទ្រនូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការសហប្រជាជាតិក្នុងការជំរុញការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន៕

ថ្ងៃសៅរ៍ ៨ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

# FOREWORD

If cities of the future could speak, what would they say?



I recently read an opinion piece titled 'It's 2059 and the Rich Kids Are Still Winning'. This provocation made me stop and think as it asks: What kind of world do we want to create?
It has also affirmed my belief that a truly radical future, is not just a technological one, but an inclusive one that does not replicate past inequalities. If we do things differently, could those headlines say 'It's 2030, and Cambodian Youth Have Won the Fight Against Inequality in Cities'?

## The future we want

The Cambodia Urban Forum in November 2019 is the start of a conversation about the future we want for Cambodia's cities. We have a long way to go, but the best way to predict that future, is to create it. Here are two important lessons we learnt unpacking urbanization:

First, who are cities for? Cities are for people. Beyond buildings and cars, cities are an answer to that original question, of how we bring people together. From tuk-tuk drivers, to school children, garment workers to grandparents, Cambodia's cities are filled with a thousand wisdoms, community solutions, and perspectives about urbanization.

How do we get these perspectives to listen and learn from each other? How do we make our cities speak in all of these ways? Citizens also face urgent challenges in terms of livability, waste, and basic services, especially for the urban poor who live in informal settlements.

Second, how should urban governance be structured? We need a whole-of-government and whole-of-society approach to ensure Cambodia's cities meet people's aspirations, including the future they want for their children and grandchildren. We also need better information for evidence-based planning, investments and policies.

What action is needed?

This Report attempts to capture these initial conversations from the Cambodia Urban Forum. Here is what we said we would work on together:

1. Advocate for a vision of sustainable urbanization
2. Strengthen the use of data to inform planning and investment decision
3. Increase urban financing provided by public and private actors
4. Create an enabling environment through urban policies and sector plans
5. Ensure the participation of all people to create people-centered urban futures

On behalf of the United Nations in Cambodia, I would like to express our sincere gratitude to the Ministry of Land Management, Urban Planning and Construction, in jointly organizing the first Cambodia Urban Forum.

As the UN turns 75 in 2020, the world faces tremendous change. We will reimagine and renew our efforts to realize the future hopes and dreams of Cambodia's children, women and men who live in its vibrant cities. I look forward to listening and learning from the people of Cambodia to realize smart, sustainable and inclusive cities, as part of UN75 conversations about the future we want, to ensure that no one is left behind.



Pauline Tamesis
Resident Coordinator
United Nations in Cambodia

# បុព្វកថា

ប្រសិនបើ និយាយអំពីទីក្រុងនាពេលអនាគត  តើអ្នកនឹងនិយាយអំពីអ្វី?
ខ្ញុំទើបតែបានអាន ឯកសារទស្សនៈមួយដែលមានចំណងជើងថា “នេះគឺឆ្នាំ ២០៥៩ ហើយក្មេងអ្នកមាននៅតែឈ្នះ”។ ការលើកឡើងបែបនេះ ធ្វើឲ្យខ្ញុំឈប់ស្ងៀម ហើយគិតដោយបានចោទជាសំនួរថា តើពិភពលោកបែបណាដែលយើងចង់បង្កើត?
នេះបានបញ្ជាក់ពីជំនឿរបស់ខ្ញុំផងដែរថា ទីក្រុងនាពេលអនាគត វាមិនត្រឹមតែជាទីក្រុងដែលបំពាក់ដោយបច្ចេកវិទ្យានោះទេ តែក៏ត្រូវជាទីក្រុងមានលក្ខណៈបរិយាបន្ន ដែលមិនអាចបន្តឲ្យមានវិសមភាពដូចពេលកន្លងមកនោះទេ។ ប្រសិនបើ យើងធ្វើអ្វីឲ្យខុសប្លែកពីនេះ តើចំណងជើងខាងលើអាចប្តូរទៅជា “នេះគឺឆ្នាំ២០៣០ ហើយ យុវជនកម្ពុជាបានប្រយុទ្ធប្រឆាំងឈ្នះនឹងវិសមភាពក្នុងទីក្រុង” បានដែរឬទេ?

## អនាគតដែលយើងចង់បាន

វេទិកានគរូបនីយកម្មកម្ពុជា នាខែ វិច្ឆិកា ឆ្នាំ ២០១៩ គឺជាការចាប់ផ្តើម កិច្ចសន្ទនាអំពីអនាគតរបស់ទីក្រុងកម្ពុជាដែលយើងចង់បាន។ យើងមានផ្លូវវែងឆ្ងាយទៀតដែលត្រូវដើរ តែមធ្យោបាយដែលល្អបំផុតក្នុងការទស្សទាយពីអនាគតនោះ គឺត្រូវបង្កើតវា។ មានមេរៀនពីរសំខាន់ៗដែលយើងទទួលបានពីសន្និសីទនៃនគរូបនីយកម្ម÷
ជាដំបូង  តើទីក្រុងសម្រាប់អ្នកណា? ទីក្រុងគឺសម្រាប់ប្រជាជន។ ក្រៅពីអគារ និង ឡាន ចម្លើយនៃសំនួរនេះ គឺទីក្រុងសម្រាប់ប្រជាជនគ្រប់គ្នា។  ចាប់ផ្តើមពីអ្នកបើកបររ៉ឺមកកង់បី សិស្សសាលា កម្មកររោងចក្រកាត់ដេរ រហូតទៅដល់ ជីដូនជីតា ទីក្រុងនៃប្រទេសកម្ពុជា ត្រូវបានបំពេញដោយ  ប្រាជ្ញាដំណោះស្រាយសម្រាប់សហ គមន៍ និង ទស្សនវិស័យអំពីនគរូបនីយកម្មរាប់ពាន់។
តើមានមធ្យោបាយណាដែល យើងអាច យកទស្សនៈទាំងនេះ មកស្តាប់ និង រៀនសូត្រពីគ្នាទៅវិញទៅមក? តើមានមធ្យោបាយណាដែលអាចធ្វើឲ្យទីក្រុងយើងនិយាយដូចនេះបាន? ប្រជាជន ក៏ជួបប្រទះនឹងបញ្ហាប្រឈមបន្ទាន់មួយចំនួនមានដូចជា ការរស់នៅ សំណល់ និង សេវាកម្មមូលដ្ឋានផ្សេងៗ ជាពិសេសសម្រាប់ប្រជាជនក្រីក្រនៅទីក្រុង ដែលរស់នៅក្នុងសំណង់មិនស្របច្បាប់។
ទីពីរ តើរចនាសម្ព័ន្ធនៃការគ្រប់គ្រងទីក្រុងគួររៀបចំយ៉ាងដូចម្តេច? យើងត្រូវការវិធីសាស្ត្រ រដ្ឋាភិបាល និង សង្គមទាំងមូល ដើម្បីធានាឲ្យទីក្រុងកម្ពុជា អាចសម្រេចសេចក្តីប៉ងប្រាថ្នារបស់ប្រជាជន រួមមានដូចជា អនាគតដែលពួកគេចង់បាន សម្រាប់កូននិងចៅរបស់ពួកគេ។ យើងត្រូវការព័ត៌មានដែលប្រសើរជាងនេះ សម្រាប់ការធ្វើផែនការដែលផ្អែកលើភស្តុតាង ការវិនិយោគ និង គោលនយោបាយ។

## តើសកម្មភាពអ្វីដែលចាំបាច់?

របាយការណ៍នេះមានគោលបំណង បង្ហាញពីចំនុចសំខាន់ៗនៃកិច្ចសន្ទនាដំបូងពីវេទិកានគរូបនីយកម្ម។ ទាំងនេះជាចំនុចដែលយើងបាននិយាយថាយើងចង់ធ្វើការជាមួយគ្នា÷

១. តស៊ូមតិដើម្បីចក្ខុវិស័យនៃនគរូបនីយកម្មប្រកបដោយចីរភាព
២. ពង្រឹងការប្រើប្រាស់ទិន្នន័យដើម្បីជាព័ត៌មានក្នុងការរៀបចំផែនការ និង ការសម្រេចចិត្តវិនិយោគ
៣. បង្កើនការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង ដោយវិស័យឯកជននិងរដ្ឋ
៤. បង្កើតបរិស្ថានដែលអំណោយផលតាមរយៈគោលនយោបាយនគរូបនីយកម្មនិងផែនការតាមវិស័យ
៥. ធានាការចូលរួមពីប្រជាជនគ្រប់គ្នា ដើម្បីបង្កើត ទីក្រុងនាពេលអនាគតដែលយកចិត្តទុកដាក់លើប្រជាជន

ក្នុងនាមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ចំពោះក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ ក្នុងកិច្ចសហការរៀបចំ វេទិកានគរូបនីយកម្មកម្ពុជាលើកទី១។ ខណៈអង្គការសហប្រជាជាតិ ឈានដល់ខួប ៧៥ ក្នុងឆ្នាំ ២០២០នេះ ពិភពលោកប្រឈមនឹងការផ្លាស់ប្តូរយ៉ាងខ្លាំង។ យើងនឹងពិចារណាឡើងវិញ និង បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឲ្យបានក្តីសង្ឃឹម និងសុបិន្តនាពេលអនាគតរបស់កុមារ ស្ត្រី និង បុរសកម្ពុជា ដែលរស់នៅក្នុង ទៅក្រុងដ៏សកម្មនេះ។ ខ្ញុំទន្ទឹងរង់ចាំ ស្តាប់និង រៀនសូត្រពីប្រជាជនកម្ពុជា ដើម្បីសម្រេចឲ្យបាននូវទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និង បរិយាបន្ន ដែលជាផ្នែកមួយនៃកិច្ចសន្ទនាអង្គការសហប្រជាជាតិទី៧៥ អំពីអនាគតដែលយើងចង់បាន ដើម្បីធានាថា យើងមិនទុកអ្នកណាម្នាក់ចោល។

លោកស្រី Pauline Tamesis
អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា
អង្គការសហប្រជាជាតិប្រចាំកម្ពុជា



# ១

# និន្នាការរួមនានា

## ១.១. ព័ត៌មានសាវតារ

នគរូបនីយកម្មនៅកម្ពុជាកំពុងមានសន្ទុះ និងវិសាលភាពធំដែលមិនធ្លាប់មានពីមុនមក។ តាមការព្យាករណ៍ផ្លូវការ នៅត្រឹមឆ្នាំ២០៣០ ប្រជាជនកម្ពុជាប្រមាណមួយភាគបីនឹងរស់នៅក្នុងតំបន់ទីប្រជុំជន១ ។ បញ្ហាប្រឈមក្នុងការពង្រីកសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដើម្បីអោយស៊ីសង្វាក់នឹងកំណើនប្រជាជន អាចនាំឱ្យមានហានិភ័យមួយចំនួនមានជាអាទិ៍ ផលប៉ះពាល់បរិស្ថាន ភាពក្រីក្រ និងហានិភ័យសេដ្ឋកិច្ច។ ដូច្នេះសក្ដានុពលសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាត្រូវពឹងផ្អែកកាន់តែខ្លាំងឡើងៗទៅលើរបៀបគ្រប់គ្រងទីក្រុង និងទីប្រជុំជន។ លោក Antonio Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិបានមានប្រសាសន៍នៅក្នុងទិវាលំនៅឋានពិភពលោកកាលពីពេលកន្លងទៅថា “**ការអភិវឌ្ឍទីក្រុងបានល្អស្របទៅតាមផែនការត្រឹមត្រូវអាចនាំឱ្យយើងទទួលបាននូវកំណើនខ្ពស់ប្រកបដោយបរិយាបន្ន និងកាត់បន្ថយបានច្រើននូវការបញ្ចេញជាតិពុលទៅក្នុងបរិយាកាស ហើយដំណោះស្រាយអាចចាប់ផ្ដើមពីជំហានតូចៗដែលបុគ្គលម្នាក់ៗអាចធ្វើបានដើម្បីផ្លាស់ប្ដូរទីក្រុង**”។

នគរូបនីយកម្មមានតួនាទីជាវិជ្ជមានប្រសិនបើភាគីនានាអាចធ្វើការរួមគ្នាតាមរយៈយន្តការសម្របសម្រួលមួយដែលទង្វើបែបនេះ នឹងបញ្ចៀសរបៀបធ្វើការដាច់ដោយឡែកពីគ្នា និងបង្កើនភាពស៊ីសង្វាក់គ្នានៃសកម្មភាពនានារបស់ពួកគេ។ ក្នុងស្ថានភាពនេះសូមអំពាវនាវឱ្យមានការដាក់ចេញនូវដំណោះស្រាយថ្មីៗបន្ថែមទៀត។

**វេទិកានគរូបនីយកម្មកម្ពុជា (Cambodia Urban Forum, CUF)** គឺជាវេទិកាពិគ្រោះយោបល់សម្រាប់ឱ្យភាគីពាក់ព័ន្ធនានាបានពិភាក្សា និងឯកភាពគ្នាលើអាទិភាពផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាដើម្បីឈានទៅសម្រេចឱ្យបាននូវការអភិវឌ្ឍទីក្រុងដែលមានលក្ខណៈឆ្លាតវៃ ប្រកបដោយបរិយាបន្ន និងចីរភាព។ វេទិកានេះក៏ជាកាលានុវត្តភាពសម្រាប់សម្របសម្រួលប្រមូលធាតុចូលសម្រាប់ដំណើរការតាមដាន និងវាយតម្លៃរបៀបវារៈអភិវឌ្ឍន៍សកល ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទី ១១ និងរបៀបវារៈ ទីក្រុងថ្មីជាដើម ដោយប្រើប្រាស់ការងារដែលបានធ្វើកន្លងមកដោយ រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងរបាយការណ៍ជាតិស្ដីពីលំនៅឋានលើកទី ៣ ក្រោមក្របខណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៩-២០២៣។

1 UNDESA, 2018, World Urbanization Prospects 2018, New York

## ១.២. វេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

**វេទិកានគរូបនីយកម្មកម្ពុជាលើកទី ១** ដែលបានធ្វើឡើងកាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៩ គឺជាវេទិកាប្រមូលផ្ដុំអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិប្រមាណជាង ២០០ នាក់ឱ្យចូលរួមក្នុងកិច្ចពិភាក្សាដែលមានលក្ខណៈបរិយាបន្នអំពីស្ថានភាពនគរូបនីយកម្មនាពេលបច្ចុប្បន្ននៅកម្ពុជា កំណត់ពីអាទិភាពនិងនិន្នាការចំបងៗ និងចែក រំលែកបទពិសោធន៍ និងចំណេះដឹងជុំវិញប្រធានបទ “**ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន**”។ វេទិកានេះត្រូវបានសហការរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការសហ- ប្រជាជាតិនៅកម្ពុជា។

វេទិកាដែលមានរបៀបវារៈសំខាន់ៗចំនួន ៥ នេះនឹងផ្ដល់លទ្ធភាពឱ្យភាគីពាក់ព័ន្ធនានាធ្វើការពិភាក្សា និងឯកភាពគ្នាលើអាទិភាពចំបងៗ ស្នើឡើងនូវយុទ្ធសាស្ត្រសម្របសម្រួល និងកំណត់អន្តរាគមន៍ផ្នែក កម្មវិធីនៅគ្រប់កម្រិតថ្នាក់នៃរាជរដ្ឋាភិបាលដើម្បីឈានទៅសម្រេច នូវចក្ខុវិស័យអភិវឌ្ឍន៍ទីក្រុងរបស់កម្ពុជាដែលមានលក្ខណៈឆ្លាតវៃប្រកបដោយចីរភាព និងបរិយាបន្ន។ វេទិកានេះមានគោលបំណងឈានទៅរកការឯកភាពគ្នាអំពីការកំណត់អាទិភាពសំខាន់ៗ និងការកំណត់ពីឈ្មោះស្ថាប័នដែលត្រូវទទួលខុសត្រូវនូវអាទិភាពនីមួយៗ។



វេទិកានេះក៏គ្រោងនឹងស្នើឡើងនូវអន្តរាគមន៍ផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីដែលផ្តោតជាសំខាន់លើការផ្តល់ហិរញ្ញប្បទាន ការអភិវឌ្ឍសមត្ថភាព នវានុវត្តន៍ ការសម្របសម្រួល និងភាពជាដៃគូជាយុទ្ធសាស្ត្រផងដែរ។

## ១.៣. របៀបវារៈនៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

នៅក្នុងកម្មវិធីបើកនៃវេទិកាដែលមានរយៈពេលពេញមួយថ្ងៃនេះ មានការថ្លែងសុន្ទរកថាគន្លឹះដោយវាគ្មិនជាតិ និងអន្តរជាតិដែលផ្តោតលើការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន។ បន្ទាប់មកនៅក្នុងរបៀបវារៈទីពីរមានការធ្វើបទបង្ហាញអំពីស្ថានភាពនគរូបនីយកម្មនាពេលបច្ចុប្បន្ន បញ្ហាប្រឈម និងកាលានុវត្តភាព។ លើសពីនេះនៅក្នុងរបៀបវារៈទីបីមានការពិភាក្សាអំពីអាទិភាពសម្រាប់ទីក្រុងនៅកម្ពុជាផងដែរ។ របៀបវារៈទីបួនផ្តោតលើការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង។ នៅក្នុងរបៀបវារៈចុងក្រោយវេទិកាត្រូវបានបញ្ចប់ជាមួយនឹងសេចក្តីថ្លែងការណ៍អំពីអាទិភាពសំខាន់ៗ និងជំហានបន្ទាប់សម្រាប់កំណត់ចក្ខុវិស័យនៃការអភិវឌ្ឍទីក្រុងនៅកម្ពុជា។ របៀបវារៈលំអិតនៃកម្មវិធីមានពណ៌នានៅក្នុងឧបសម្ព័ន្ធទី ១។

**វត្ថុបំណង**

**ហេតុអ្វី?**

១. **ចែករំលែកចំណេះដឹង និងបទពិសោធន៍** អំពីការអភិវឌ្ឍនគរូបនីយកម្មដែលនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សាកម្រិតគោលនយោបាយរវាងភាគីពាក់ព័ន្ធចម្រុះផ្តោតលើស្ថានភាពចុងក្រោយនៃការអភិវឌ្ឍ និងការពង្រីកទីក្រុង ដោយផ្តោតលើនិន្នាការ បញ្ហាសំខាន់ៗ ដំណោះស្រាយ និង/ ឬការអនុវត្តល្អៗ។ ទិដ្ឋភាពរួមបែបនេះ អាចជាទិដ្ឋភាពរួមនៅកម្រិតសកលលោក កម្រិតតំបន់ ឬនៅក្នុងប្រទេសមួយ។

**អ្វីខ្លះ?**

២. **ពិភាក្សានិងឯកភាពគ្នាលើអាទិភាពសម្រាប់ទីក្រុងដែល**ជួយកំណត់នូវចក្ខុវិស័យរបស់កម្ពុជាសម្រាប់ទីក្រុងឱ្យមាន

លក្ខណៈឆ្លាតវៃ ចីរភាព និងបរិយាបន្ន។ ការកំណត់ពីចក្ខុវិស័យនៃការអភិវឌ្ឍ និងពង្រីកទីក្រុងនៅកម្ពុជា គប្បីត្រូវធ្វើឡើងផ្អែកតាមគោលនយោបាយស្តីពីការអភិវឌ្ឍ និងការពង្រីកទីក្រុងដែលមានលក្ខណៈ បរិយាបន្ន និងអាចសម្រេចទៅបានតាមរយៈការអនុវត្តអន្តរាគមន៍ផ្អែកយុទ្ធសាស្ត្រ និងកម្មវិធីដែលមានលក្ខណៈស៊ីសង្វាក់ និងមានការសម្របសម្រួលជាមួយគ្នានៅគ្រប់កម្រិតទាំងអស់របស់រាជរដ្ឋាភិបាល។ ដូច្នេះនៅក្នុងវេទិកានេះមានការឯកភាពគ្នាលើប្រធានបទតាមវិស័យសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង រួមនឹងការ បែងចែកតួនាទីភារកិច្ចដល់ស្ថាប័នដឹកនាំការអនុវត្ត។

**ដោយរបៀបណា?**

៣. **ពិភាក្សានិងឯកភាពគ្នាលើជំហានបន្ទាប់**ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗដែលបានឯកភាពគ្នា។ ជំហានបន្ទាប់ទាំងនេះរួមមាន សំណើអន្តរាគមន៍ដែលស្នើឡើងផ្អែកគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ផ្តោតលើការផ្តល់ហិរញ្ញប្បទាន ការអភិវឌ្ឍសមត្ថភាព នវានុវត្តន៍ ការសម្របសម្រួល និងភាពជាដៃគូយុទ្ធសាស្ត្រ រួមជាមួយនឹងវិស័យឯកជន ការវិនិយោគលើគម្រោងដែលអាចទទួលបានហិរញ្ញប្បទានពីធនាគារដែលសម្រេចតាមគោលដៅអភិវឌ្ឍន៍ដោយចីរភាព ។

## ១.៤. ព័ត៌មានសង្ខេបអំពីអ្នកចូលរួមវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

នៅក្នុងវេទិកានេះ មានអ្នកចូលរួមសរុប ២៣៦ នាក់ ដូចបង្ហាញក្នុងតារាងសង្ខេបខាងក្រោម និងបង្ហាញលំអិតក្នុង**ឧបសម្ព័ន្ធទី ២**។

| ល.រ. | ប្រភេទ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | ក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា | ៣៨ |
| ២ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ២៥ |
| ៣ | រដ្ឋបាលរាជធានី ខេត្ត | ២៥ |
| ៤ | ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថានទូត | ៤៨ |
| ៥ | អង្គការអន្តរជាតិអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល | ១០ |
| ៦ | ស្ថាប័នសិក្សាស្រាវជ្រាវ | ៤១ |
| ៧ | វិស័យឯកជន | ៣៥ |
| ៩ | អ្នកសារព័ត៌មាន | ១៤ |
| សរុប | | ២៣៦ |

# ២

# របាយការណ៍សង្ខេបអំពីវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

## ២.១. ពិធីបើកវេទិកា

វេទិកាដែលមានរយៈពេលពេញមួយថ្ងៃនេះបានចាប់ផ្តើមជាមួយនឹងការថ្លែងសុន្ទរកថាគន្លឹះពីអ្នកជំនាញនគរូបនីយកម្មអន្តរជាតិ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការសហប្រជាជាតិ អំពីទីក្រុងឆ្លាតវៃប្រកបដោយចីរភាព និងបរិយាបន្ន។

វាគ្មិននៅក្នុងកម្មវិធីនេះរួមមាន÷

- លោកស្រីPauline Tamesis អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា
- លោកស្រី Gabriella Gomez-Mont ប្រធានក្រុមការងារអភិវឌ្ឍន៍ទីក្រុង និងជាអតីតប្រធានផ្នែកគំនិតច្នៃប្រឌិតរបស់ទីក្រុងម៉ិកស៊ិកូ
- បណ្ឌិត Kim Kyunghwan សាស្ត្រាចារ្យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Sogang University និងជាអតីតរដ្ឋមន្ត្រី ស្តីទីក្រសួងដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍នៃ ប្រទេសកូរ៉េ
- ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** រដ្ឋលេខាធិការ តំណាង ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អ្នកសម្របសម្រួល÷ លោក **ម៉ុល វិបុល** មកពីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**វាគ្មិន÷ លោកស្រី Pauline Tamesis អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា**

លោកស្រីTamesis បានថ្លែងសុន្ទរកថាបើកដោយរំលឹកឡើងវិញពីវត្ថុបំណងសំខាន់ៗនៃវេទិកានេះ ដើម្បីចែករំលែកចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុង និងកំណត់ពីអាទិភាពសំខាន់ៗក្នុងការឈានទៅអភិវឌ្ឍទីក្រុងឆ្លាតវៃប្រកបដោយចីរភាព និងបរិយាបន្ន។ លោកស្រីបានគូសបញ្ជាក់ថា ការអភិវឌ្ឍទីក្រុងដែលមានផែនការច្បាស់លាស់និងមានការគ្រប់គ្រងបានល្អ គឺជាកម្លាំងចលករដ៏មានអានុភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ ទីក្រុងនាពេលអនាគតដែលប្រកបចីរភាព និងយកចិត្តទុកដាក់លើតម្រូវការរបស់ប្រជាពលរដ្ឋ គឺជាគន្លឹះនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងទីក្រុង សំដៅគាំទ្រដល់ការសម្រេចបាននូវ



វិបុលភាពរយៈពេលវែងសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ នៅចុងបញ្ចប់នៃសុន្ទរកថា លោកស្រីបានផ្តល់នូវអនុសាសន៍សំខាន់ៗចំនួន ៥ សម្រាប់ពិនិត្យតាមដានបន្តទៀតបន្ទាប់ពីវេទិកានេះ។

**វាគ្មិន÷ លោកស្រី Gabriella Gomez-Mont ប្រធានក្រុមការងារអភិវឌ្ឍន៍ទីក្រុង និងជាអតីតប្រធានផ្នែកគំនិតច្នៃប្រឌិតរបស់ទីក្រុងម៉ិកស៊ិកូ**

លោកស្រី Gomez-Month បានចែករំលែកបទពិសោធន៍ជុំវិញការពង្រីកបរិវេណសាធារណៈនៅក្នុងទីក្រុងម៉ិកស៊ិកូ ការរៀបចំយុទ្ធសាស្ត្រផ្អែកតាមការស្វែងយល់ពីចរិកលក្ខណៈ(DNA) របស់ទីក្រុង និងអំពីភាពរស់រវើករបស់ទីក្រុង និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋអំពីអនាគតទីក្រុង។ ការប្រមូលទិន្នន័យ គឺជាបញ្ហាប្រឈមដំបូងដែលត្រូវដោះស្រាយ។ លោកស្រីក៏បានគូសបញ្ជាក់ផងដែរថាអ្នកដែលពូកែគិតស្រមៃពីអ្វីដែលនឹងកើតមាននៅក្នុងសង្គម គឺជាអ្នកដែលមានតួនាទីសំខាន់ក្នុងការស្វែងរកដំណោះស្រាយសម្រាប់ទីក្រុង។ សិទ្ធិរស់នៅក្នុងទីក្រុង គឺជាកត្តាមួយទៀតដែលត្រូវយកមកធ្វើការពិចារណា។ រដ្ឋធម្មនុញ្ញនៃទីក្រុងម៉ិកស៊ិកូបានផ្តល់ការការពារដល់សិទ្ធិមនុស្ស និងចែងពីអ្វីដែលទីក្រុងអាចធ្វើបាន ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ ប្រការនេះធ្វើឱ្យគេកាន់តែអាចស្រមើស្រមៃពីអ្វីដែលអាចកើតមាននៅក្នុងទីក្រុង។



**វាគ្មិន÷ បណ្ឌិត Kim Kyunghwan សាស្ត្រាចារ្យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Sogang University និងជាអតីតរដ្ឋមន្ត្រីស្តីទីក្រសួងដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍នៃប្រទេសកូរ៉េ**

បណ្ឌិត Kim បានគូសបញ្ជាក់ថា “ទីក្រុងឆ្លាតវៃ” មិនមែនជាគោលដៅនោះឡើយ ប៉ុន្តែជាអភិក្រមដែលជួយសម្រេច ឱ្យបាននូវទីក្រុង ដែលមានសុវត្ថិភាព បរិយាបន្ន ភាពធន់ និងចីរភាព។ ទីក្រុងគឺជាវេទិកាបើក ចំហដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ ប្រទេសកូរ៉េ គឺជាប្រទេសដំបូងដែលបានអនុវត្តគោលនយោបាយស្តីពីទីក្រុងឆ្លាតវៃ។ ឧទាហរណ៍អំពីដំណោះស្រាយទីក្រុងឆ្លាតវៃ រួមមាន÷ មជ្ឈមណ្ឌលត្រួតពិនិត្យរួម ប្រព័ន្ធទិន្នន័យព័ត៌មានចល័ត ប្រព័ន្ធព័ត៌មានអំពីមធ្យោបាយដឹកជញ្ជូនសាធារណៈ ប្រព័ន្ធចោលសំរាមដោយស្វ័យប្រវត្តិ កាមេរ៉ាសុវត្ថិភាព (CCTV) ដែលបំពាក់នៅតាមឧទ្យានជាប់មាត់បឹង។ល។ លោកបានលើកឡើងថា រដ្ឋាភិបាល ថ្នាក់ជាតិត្រូវបង្កើតនូវក្របខណ្ឌ និងចូលរួមសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងវិស័យឯកជន ក្នុងការអនុវត្តប្រតិបត្តិការការងារ ការអនុវត្តការងារថែទាំ និងការកែលម្អដំណោះស្រាយនានា។ ការអនុវត្តគួរធ្វើឡើងដើម្បីច្បាមយកឱកាសដែលមាន និងត្រូវមាន ភាព បត់បែនដោយត្រូវពិចារណាអំពីតម្រូវការនិងសមត្ថភាព។ ការប្រើប្រាស់ និងការវិភាគទិន្នន័យឱ្យបានល្អបំផុតក៏ជាគន្លឹះសំខាន់ផងដែរ។



**វាគ្មិន÷ ឯកឧត្តមបណ្ឌិត ប៉ែន សុផល រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** បានវាយតម្លៃខ្ពស់ដល់ការរៀបចំវេទិកានេះ ដើម្បីចែករំលែកនូវទស្សនៈគន្លឹះ ក្នុងការឆ្ពោះទៅរកចក្ខុវិស័យរួមគ្នាគឺ“**ការអភិវឌ្ឍទីក្រុងកម្ពុជាប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន**” មានជាអាទិ៍ការចែករំលែកចំណេះដឹងបទពិសោធន៍នៃការអភិវឌ្ឍ គោលនយោបាយ ចក្ខុវិស័យយុទ្ធសាស្ត្រ វិស័យអាទិភាព ការពង្រីកទីក្រុង ការអភិវឌ្ឍន៍ទីក្រុង ការអភិវឌ្ឍដី សហគមន៍ឆ្លាតវៃ បរិយាបន្ន ស្ថានភាពទីក្រុង បញ្ហាប្រឈម ដំណោះស្រាយ និន្នាការ កាលានុវត្តភាព នវានុវត្តន៍ ការសម្របសម្រួល ភាពជាដៃគូ ការផ្តល់ហិរញ្ញប្បទាន ការកសាងសមត្ថភាព ការការពារធនធានធម្មជាតិនិងបរិស្ថាន ការការពារគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង។ កម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានការលើកទឹកចិត្តដល់ការវិនិយោគដោយច្បាប់ មានប្រជាពលរដ្ឋសកម្មក្នុងវ័យពលកម្មច្រើនលើសលប់ប្រកបដោយការប្រកួតប្រជែង សេវារដ្ឋបាលដែលបម្រើដល់ធុរកិច្ចនិងការវិនិយោគមានភាពងាយស្រួលដោយអនុវត្តប្រព័ន្ធច្រកចេញ-ចូលតែមួយ របបកម្មសិទ្ធិដីធ្លីមានប្រព័ន្ធសុរិយោដីចុះបញ្ជីច្បាស់លាស់តាមគោលការណ៍នីតិរដ្ឋដោយបានចុះបញ្ជីដីធ្លីបានជាង ៥,៤ លានប័ណ្ណត្រូវជា៧៨,០៧% នៃក្បាលដីសរុបប្រមាណ ៧ លានក្បាលដី និងគ្រោងនឹងបញ្ចប់ ១០០% នៅឆ្នាំ២០២១។

គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានសម្រេចដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល បានកំណត់ច្បាស់អំពីចក្ខុវិស័យថា “**ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់**




ភូមិសាស្ត្រនីមួយៗ” ដោយបានកំណត់យុទ្ធសាស្ត្រតំបន់ប៉ូល អភិវឌ្ឍជាតិ តំបន់ស្នូល និងអ័ក្សនៃការអភិវឌ្ឍជាតិ ដែលមានសក្តានុពល និងអាទិភាពសម្រាប់ អភិវឌ្ឍ និង អភិរក្សធនធានធម្មជាតិ ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច។ ដើម្បី ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនគរូបនីយកម្ម និងការគ្រប់គ្រងការអភិវឌ្ឍអចលនទ្រព្យ និងសំណង់ ច្បាប់ស្តីពីសំណង់ត្រូវបានអនុម័ត និង ប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដោយមានគោលការណ៍សំខាន់គឺការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន ការរៀបចំដែនដីនិងនគរូបនីយកម្ម ការអភិវឌ្ឍបៃតង ការការពារធនធានធម្មជាតិនិងបរិស្ថាន ព្រមទាំងការរក្សានិងលើកកម្ពស់ អត្តសញ្ញាណជាតិ។ ការអភិវឌ្ឍនគរូបនីយកម្ម អចលនទ្រព្យ និងសំណង់កំពុងមានកំណើនក្នុងសន្ទុះដ៏លឿនបានក្លាយជាសសរស្តម្ភស្នូលនៃការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុង ១ឆ្នាំ។ ក្នុងករណីនេះ យើងអាចមើលឃើញពីតម្រូវការនៃការវិនិយោគ ការរៀបចំ ការអភិវឌ្ឍ និងការគ្រប់គ្រងការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្នដែលមានភាពធន់ និងមានភាពប្រកួតប្រជែងខ្ពស់យ៉ាងដូចម្តេច? ដើម្បីធានាបាននូវម៉ាក្រូសេដ្ឋកិច្ចរឹងមាំបន្តទៀត និងឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងនៅឆ្នាំ ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់ មានជាអាទិ៍ការអភិវឌ្ឍលំនៅឋាន ជាពិសេសការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិស្ថាន សេដ្ឋកិច្ច សង្គម បណ្តាញផ្លូវ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ប្រព័ន្ធលូ ប្រព័ន្ធការពារទឹកជំនន់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់រឹងរាវ លំហសាធារណៈនិងផ្ទៃបៃតង បរិក្ខារទីក្រុង។ល។

## ២.២. ទិដ្ឋភាពរួមទូទៅអំពីនគរូបនីយកម្ម៖ ស្ថានភាព បញ្ហាប្រឈម និងកាលានុវត្តភាព

នៅក្នុងវគ្គទី ២ នៃវេទិកានេះ មានការបង្ហាញទិដ្ឋភាពរួមទូទៅ អំពីស្ថានភាពនគរូបនីយកម្មបច្ចុប្បន្នក្នុងប្រទេសកម្ពុជា ការលើកឡើងពីបញ្ហាប្រឈម និងកាលានុវត្តភាពនានា។

វាគ្មិននៅក្នុងកម្មវិធីនេះរួមមាន៖

- ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លោក Stefanos Fotiou នាយកផ្នែកបរិស្ថាន និងការ អភិវឌ្ឍនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP)
- បណ្ឌិត Frank Rijsberman អគ្គនាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល
- លោកស្រី **គួ ស៊ីណា** ប្រធានកម្មវិធីអភិវឌ្ឍន៍ទីក្រុងសម្រាប់ស្ត្រីក្រីក្រ
- អ្នកសម្របសម្រួល៖ លោក Laxman Perera មន្ត្រីលំនៅឋានមនុស្សជាតិ នៃការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក កម្មវិធីលំនៅឋានមនុស្សជាតិរបស់អង្គការ សហប្រជាជាតិ

**វាគ្មិន៖ ឯកឧត្តមបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

បច្ចុប្បន្ននេះ កម្ពុជាមានប្រជាជនសរុបចំនួន ១៦,២៤ លាននាក់(២ លាននាក់រស់នៅក្នុងរាជធានី)។ តាមការសិក្សាអំពីនគរូបនីយកម្មឆ្នាំ ២០១៥ នគរូបនីយកម្មមានកម្រិត ២៧,១% ក្នុងឆ្នាំ ២០០៨ និង ៣០% ក្នុងឆ្នាំ ២០១៤ ហើយត្រូវបានប៉ាន់ប្រមាណថា នឹងកើនឡើងដល់ប្រមាណ ៤៤% ក្នុងឆ្នាំ ២០៣០។ មានវិស័យជាច្រើនដែលជួយជំរុញកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជាមានដូចជា៖ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកម្មន្តសាល។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា មានសសរស្តម្ភចំនួន ៤ ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព ក្នុងនោះសសរ



ស្តុម្ភចំនួន ៣ បានលើកឡើងពីការរៀបចំដែនដី។ គោលនយោបាយ ជាតិស្តីពីនគរូបនីយកម្មត្រូវបានរៀបចំឡើងនៅ÷ ១). ថ្នាក់ជាតិ និង ២). ថ្នាក់ក្រោមជាតិ។

**វាគ្មិន÷ លោកStefanos Fotiou នាយកផ្នែកបរិស្ថាន និងការអភិវឌ្ឍនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP)**

ពិភពលោកនាពេលអនាគតចាំបាច់ត្រូវតែជាពិភពលោកដែលពុំមានបំភាយឧស្ម័នកាបូន។ ក្នុងឆ្នាំ ២០១៥ ពិភពលោកបានអនុម័តនូវផែនការមួយប្រកបដោយមហិច្ឆតាខ្ពស់ដើម្បីទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់។ យើងត្រូវសម្រេចឱ្យបាននូវការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ចំនួន ៤៥% នៅត្រឹមឆ្នាំ ២០៣០ និងធ្វើឱ្យកាបូនដែលបំភាយ និងកាបូនដែលត្រូវបានស្របមានបរិមាណស្មើគ្នានៅត្រឹមឆ្នាំ ២០៥០។ បរិយាបន្នសង្គម និងការការពារបរិស្ថានគឺជាគន្លឹះសម្រាប់លើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព។ ទីក្រុងកំពុងមានការរីកចម្រើននិងកាន់តែមានភាពស្មុគស្មាញ ប៉ុន្តែទីក្រុងក៏អាចជួយ ដោះស្រាយបញ្ហាទាំងនេះផងដែរតាមរយៈការធ្វើឱ្យចរន្តនគរូបនីយកម្មនាពេលអនាគតកាន់តែមានចីរភាព ការធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាពដើម្បីផ្តល់ឱកាស និងផលប្រយោជន៍ដល់ប្រជាជន។

**វាគ្មិន÷ បណ្ឌិត Frank Rijsberman អគ្គនាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)**

ការបំពុលខ្យល់មានកម្រិតធ្ងន់ធ្ងរយ៉ាងខ្លាំង ហើយបានក្លាយជាវិបត្តិមួយនៅតាមបណ្តាទីក្រុងជាច្រើនទូទាំងអាស៊ី។ ទីក្រុងត្រូវដាក់ចេញនូវដំណោះស្រាយសម្រាប់ទាំងអស់គ្នា។ ទីក្រុងចាំបាច់ត្រូវការពារប្រជាជនពីហានិភ័យប្រឈមនឹងគ្រោះមហន្តរាយដូចជាគ្រោះទឹកជំនន់ជាដើម។ ទីក្រុងចាំបាច់ត្រូវគ្រប់គ្រងចរាចរណ៍ និងចាំបាច់ត្រូវមានដំណោះស្រាយដែលមានលក្ខណៈនវានុវត្តន៍សម្រាប់ការដឹកជញ្ជូន ព្រោះថាការប្រើប្រាស់មធ្យោបាយដឹកជញ្ជូននាបច្ចុប្បន្ននេះ ដូចជារថយន្តក្រុងជាដើម ជាកត្តាធ្វើឱ្យការបំពុលខ្យល់កាន់តែមានសភាពធ្ងន់ធ្ងរ។ ការកែច្នៃសំណល់មានសារៈសំខាន់យ៉ាងខ្លាំង និងអាចផលិតឥន្ធនៈឬអគ្គិសនីបាន។ ជាមួយនឹងគោលនយោបាយឆ្លាតវៃរបស់រាជរដ្ឋាភិបាល និងការផ្តល់ហិរញ្ញប្បទានក្នុងរូបភាពជាសម្បទានដែលមានការប្រើប្រាស់បានយ៉ាងល្អ យើងអាចទាក់ទាញការវិនិយោគពីវិស័យឯកជនលើការបម្លែងសំណល់ជាថាមពល ការប្រើរថយន្តអគ្គិសនីសម្រាប់ផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត និងដំណោះស្រាយទីក្រុងបៃតងផ្សេងទៀត។

**វាគ្មិន÷ លោកស្រី គូ ស៊ីណា ប្រធានកម្មវិធីអភិវឌ្ឍន៍ទីក្រុងសម្រាប់ស្ត្រីក្រីក្រ**

ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គួរចាំបាច់ត្រូវធានាឱ្យមានការផ្តល់លំនៅឋានដែលមានតម្លៃសមរម្យសម្រាប់ក្រុមដែលមានប្រាក់ចំណូលទាប និងក្រុមដែលងាយរងគ្រោះទាំងអស់នៅក្នុង ប្រទេស និងចាំបាច់ត្រូវធានាយ៉ាងណាឱ្យសហគមន៍មានភាពជាម្ចាស់ លើគម្រោងសាងសង់និងគម្រោងអភិវឌ្ឍន៍ថ្មីៗ។ រាជរដ្ឋាភិបាលគួរដាក់ចេញនូវគោលនយោបាយ ច្បាប់ និង/ ឬបទដ្ឋានរួមដើម្បីឆ្លើយ តបចំពោះបញ្ហាដែលកើតមាននៅក្នុងទីក្រុង ដូចជាច្បាប់ស្តីពីដីធ្លីសម្រាប់ប្រជាពលរដ្ឋដែលគ្មានដីធ្លីជាដើម។ រាជរដ្ឋាភិបាលគួរបង្កើនលទ្ធភាពរបស់ប្រជាពលរដ្ឋដើម្បីទទួលបានព័ត៌មានដែលត្រឹមត្រូវ និងអាចជឿទុកចិត្តបាន និងផ្តល់ឱកាសឱ្យពួកគេអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងដំណើរការអភិវឌ្ឍន៍ទីក្រុង។ រាជរដ្ឋាភិបាលគួរមានការសាងសង់លំហសាធារណៈ និងសម្ភារៈរូបវន្តផ្សេងៗ ដូចជាសួនច្បារ និងកន្លែងចតរថយន្តជាដើម និងគួរមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មុនពេលរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង ព្រមទាំងចាំបាច់ត្រូវមានការគ្រប់គ្រងសំណល់រាវនិងរឹងឱ្យបានត្រឹមត្រូវ។ រាជរដ្ឋាភិបាលគួរមានការកែលម្អប្រព័ន្ធដឹកជញ្ជូន សាធារណៈ និងគួរមានការការពារអគារប្រវត្តិសាស្ត្រចាស់ៗដើម្បីផ្សព្វផ្សាយពីអត្តសញ្ញាណជាតិ និង

លើកកម្ពស់វិស័យទេសចរណ៍។ រាជរដ្ឋាភិបាលគួរមានការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។

**អនុសាសន៍÷**

ខណៈពេលដែលការអភិវឌ្ឍទីក្រុងនៅកម្ពុជាកំពុងកើតមានក្នុងសន្ទុះមួយដ៏ឆាប់រហ័សហើយទន្ទឹមគ្នាក៏នាំមកនូវបញ្ហាប្រឈមដែលមិនអាចចៀសរួចដូចជា÷ ការកកស្ទះចរាចរណ៍ និងការបំពុលបរិស្ថាន ជាដើម ការរៀបចំផែនការគ្រប់គ្រងទីក្រុងឱ្យបានកាន់តែល្អប្រសើរអាចរួមចំណែកដោះស្រាយបញ្ហាទាំងនេះតាមរយៈការធ្វើយ៉ាងណាឱ្យការអភិវឌ្ឍទីក្រុងនាពេលអនាគតកាន់តែមាន ចីរភាព ផ្តល់ឱកាស និងអត្ថប្រយោជន៍កាន់តែប្រសើរដល់ប្រជាជន។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលបានចាត់ទុកការរៀបចំដីធ្លីជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង ៤ ដើម្បីឈានទៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន និងជាលិខិតុបករណ៍ដ៏សំខាន់មួយសម្រាប់រាជរដ្ឋាភិបាលក្នុងការកសាងនូវបរិយាកាសអំណោយផលសម្រាប់ការរៀប ចំ និងការគ្រប់គ្រងទីក្រុងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងពេលជាមួយគ្នា អាជ្ញាធរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចាំបាច់ត្រូវធានាឱ្យមានលំនៅឋានក្នុងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា ក៏ដូចជាសិទ្ធិកាន់កាប់ដីធ្លីដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើគ្រួសារដែលមានចំណូលទាប និងក្រុមដែលងាយរងគ្រោះ។ ការជំរុញឱ្យមានការចូលរួមពីសង្គមស៊ីវិល រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រដែលរស់នៅក្នុងទីក្រុងផងដែរនោះ គឺជាអភិក្រមមួយក្នុងចំណោមអភិក្រមដែលងាយស្រួលអនុវត្តជាងគេដើម្បីធានាយ៉ាងណាឱ្យមានការជំរុញអាទិភាពទីក្រុងក្នុងរយៈពេលវែង។



## ២.៣. ការកំណត់ពីអាទិភាពទីក្រុងរបស់ប្រទេសកម្ពុជា ÷ ការជំរុញលើកកម្ពស់គោលនយោបាយ និងការសម្រេចឱ្យបាននូវទីក្រុងប្រកបដោយចីរភាព

នៅក្នុងវគ្គទី ៣ នៃវេទិកា យើងធ្វើការកំណត់អាទិភាព និងសកម្មភាពដែលត្រូវធ្វើសម្រាប់រៀបចំ និងអនុវត្តគោលនយោបាយ និង កម្មវិធីលើកកម្ពស់ការអភិវឌ្ឍទីក្រុង។

វាគ្មិននៅក្នុងកម្មវិធីនេះរួមមាន÷

- ឯកឧត្ត ម **ស៊ុ យ សេរិទ្ធ** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ
- លោក**តាំងម៉េងអៀង**ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព នៃក្រសួងបរិស្ថាន
- លោកស្រី Sandrine Capelle- Manuel ប្រធានគ្រប់គ្រង ពហុការិយាល័យ អង្គការ UNOPS ប្រចាំប្រទេសកម្ពុជា
- អ្នកសម្របសម្រួល÷ លោកស្រី Kristin Parco ប្រធាន បេស កកម្មអង្គការ IOM ប្រចាំប្រទេសកម្ពុជា

**វាគ្មិន÷ ឯកឧត្តម ស៊ុយ សេរិទ្ធ អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ**

ភ្នំពេញដែលជារាជធានីរបស់ប្រទេសកម្ពុជាមានផែនការជាច្រើនពាក់ព័ន្ធនឹងនគរូបនីយកម្ម ដូចជាប្លង់គោលប្រើប្រាស់ដី ចក្ខុវិស័យឆ្នាំ ២០៣៥ ផែនការមេស្តីពីវិស័យដឹកជញ្ជូនឆ្នាំ ២០៣៥ ផែនការមេស្តីពីការកែលម្អប្រព័ន្ធលូ និងគ្រប់គ្រងទឹកស្អុយឆ្នាំ ២០៣៥ ផែនការអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០១៨-២០៣០ ជាដើម។ ដើម្បី ប្រែក្លាយរាជធានីភ្នំពេញជាទីក្រុងបៃតង សាលារាជធានីភ្នំពេញនឹងគ្រោងដាំដើមឈើចំនួន ៤០ ០០០ ដើម នៅតាមទីកន្លែងនានា ដូចជា សាលារៀន វត្តអារាម មន្ទីរពេទ្យ តាមបណ្តោយផ្លូវ និងតាមមាត់ទន្លេជាដើម។ រាជធានីភ្នំពេញបានដាក់ចេញនូវអាទិភាពចំនួន ៨ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរបស់ខ្លួនជាទីក្រុងដែលមានបរិយាបន្ន



ភាពធន់ និងចីរភាព ដូចជាការរៀបចំផែនការអភិវឌ្ឍន៍ ទីក្រុង ការឆ្លើយតបចំពោះភាពងាយរងគ្រោះ ថាមពល ការដឹកជញ្ជូន បរិស្ថាន សំណង់ ផលិតកម្ម(រោងចក្រ) ការគ្រប់គ្រងសំណល់រឹង កាអភិវឌ្ឍលំហសាធារណៈ និងការការពារបេតិកភណ្ឌវប្បធម៌។

**វាគ្មិន÷ លោក តាំង ម៉េងអៀង ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព នៃក្រសួងបរិស្ថាន**

ចំនួនប្រជាជននៅក្នុងទីក្រុងមានប្រមាណជាង២៧ % នៃចំនួនប្រជាជនសរុបដែលក្នុងនោះមានប្រជាជនប្រមាណ ១២% រស់នៅប្រមូលផ្តុំក្នុងរាជធានីភ្នំពេញ (NIS, ២០១៤) ហើយមានការប៉ាន់ប្រមាណថាក្នុងឆ្នាំ ២០៣០ នឹងមានប្រជាជនចំនួន ៣៦,៣% រស់នៅក្នុងតំបន់ទីក្រុង។ ផែនការអភិវឌ្ឍន៍ទីក្រុងប្រកបដោយចចីរភាពសម្រាប់រាជធានីភ្នំពេញត្រូវបានប្រកាសផ្សព្វផ្សាយដែលផ្តល់ឱ្យភាគីពាក់ព័ន្ធសំខាន់ៗនូវផែនទីបង្ហាញផ្លូវឆ្ពោះទៅសម្រេចឱ្យបាននូវការអភិវឌ្ឍបៃតង។ ផែនការយុទ្ធសាស្ត្រស្តីពីទីក្រុងប្រកបដោយចីរភាពសម្រាប់ទីក្រុងកម្រិតទី ២ កំពុងត្រូវបានធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ចប់។ ផែនការទាំងនេះត្រូវបានលើកឡើងនូវទស្សនទានដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយផ្តោតលើកំណើនសេដ្ឋកិច្ចបៃតងក្នុងទីក្រុង បរិយាបន្នសង្គម និងភាពធន់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាច្រើនដែលកំពុងកើតមាននៅក្នុងទីក្រុងមានដូចជា÷ ថាមពល ការដឹកជញ្ជូន ការសាងសង់អគារនិងលំហសាធារណៈ ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូ និងបញ្ហាទឹកកខ្វក់។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាពបានរៀបចំគោលការណ៍ណែនាំថ្មី និងកម្មវិធីផ្តល់វិញ្ញាបនបត្របញ្ជាក់សម្រាប់អគារបៃតង។

**វាគ្មិន÷ លោកស្រី Sandrine Capelle- Manuel ប្រធានគ្រប់គ្រងពហុការិយាល័យអង្គការ UNOPS**

ទន្ទឹមគ្នានឹងនគរូបនីយកម្មកាន់តែមានភាពស្មុគស្មាញ និងប្រទាក់ក្រឡាគ្នា ឱកាសនិងហានិភ័យថ្មីៗនៃការអភិវឌ្ឍក៏ត្រូវបានបង្កើតឡើងផងដែរ។ នគរូបនីយកម្មគួរត្រូវដើរស្របគ្នាទៅនឹងការស្វែងយល់ឱ្យបានច្បាស់ពីបាតុភូតនគរូបនីយកម្មផ្សេងៗរួមមាន ភាពក្រីក្រ កង្វះហេដ្ឋារចនាសម្ព័ន្ធ ការធ្វើចំណាកស្រុកក្នុងប្រទេស សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការផ្តល់ហិរញ្ញប្បទាន។ ដូច្នេះចាំបាច់ត្រូវមានអភិក្រម

រួមមួយដែលគ្របដណ្តប់លើវិស័យជាច្រើននៅគ្រប់កម្រិត និងមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះដើម្បីអាចដោះស្រាយជាមួយនឹងបរិបទទីក្រុងទូលំទូលាយ។ ការគ្រប់គ្រង និងការចែកចាយប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់ណាស់ក្នុងប្រព័ន្ធទីក្រុងរួមមាន ស្ថាប័នពាក់ព័ន្ធ ធនធាន និងចំណេះដឹង។ វិធីសាស្ត្រសម្រាប់អភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាពដោយប្រើប្រាស់ទិន្នន័យភូមិសាស្ត្រតាមមូលដ្ឋាននីមួយៗក៏មានសារៈសំខាន់ផងដែរដើម្បីធានាយ៉ាងណាឱ្យមានការរៀបចំផែនការផ្អែកតាមភស្តុតាង និងយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ប្រជាជន។ បន្ទាប់មកក៏ត្រូវរៀបចំនូវគំរូហិរញ្ញវត្ថុសម្រាប់អនុវត្តន៍ផែនការទាំងនេះ។

**អនុសាសន៍÷**

ដើម្បីស្វែងរកវិធីសាស្ត្រក្នុងការកសាងទីក្រុងដែលមានលក្ខណៈបរិយាបន្ន ភាពធន់ និងចីរភាព ការរៀបចំផែនការរយៈពេលវែង ក្របខណ្ឌគោលនយោបាយ និងអន្តរាគមន៍កម្មវិធីផ្សេងៗដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់មានសារៈសំខាន់យ៉ាងខ្លាំង។ រាជធានីភ្នំពេញបានបង្ហាញឱ្យឃើញថា អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលបញ្ចូលកំណើនសេដ្ឋកិច្ចបៃតងនៅក្នុងទីក្រុង បរិយាបន្នសង្គម និងភាពធន់កំពុងជួយដល់ការអភិវឌ្ឍទីក្រុងទាំងនាពេលបច្ចុប្បន្ន និងនៅពេលអនាគត ហើយក្នុងពេលជាមួយគ្នាមានការឆ្លើយតបចំពោះបញ្ហាជាច្រើនដែលកើតមាននៅក្នុងទីក្រុងតាមបែបរួមចម្រុះ។ ដើម្បីសម្រេចគោលដៅនេះចាំបាច់ត្រូវមានការអនុវត្តអភិក្រមពហុវិស័យដែលមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះនៅគ្រប់កម្រិតទាំងអស់។

## ២.៤. ការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង

នៅក្នុងវគ្គទី ៤ នៃវេទិកាបានធ្វើការពិភាក្សាពីការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង និងតួនាទីដ៏សំខាន់របស់វិស័យឯកជននៅក្នុងដំណើរការនៃការអភិវឌ្ឍទីក្រុង។



វាគ្មិននៅក្នុងកម្មវិធីនេះរួមមាន÷

- លោក **ហ៊ួយ វិចិត្រ** តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លោក **ជ័យ សម្បត្តិផល្លា** ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយលេខាធិការដ្ឋានគណៈ
- កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
- លោក **Ajay Suri** អ្នកគ្រប់គ្រងកម្មវិធីសម្ព័ន្ធភាពទីក្រុងក្នុងតំបន់អាស៊ី (Cities Alliance Asia)
- បណ្ឌិត **តាន់ មុន្នីវណ្ណ** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា
- អ្នកសម្របសម្រួល÷ លោក **ហ៊ាង ផាត** អ្នកឯកទេសនៃកម្មវិធីអភិវឌ្ឍន៍ទីក្រុងនៃមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)

**វាគ្មិន÷ លោក ហ៊ួយ វិចិត្រ តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

រចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិចែកជា ៣ កម្រិត ÷ ទី ១)រាជធានី ខេត្ត(២៥) ទី ២)ក្រុង ស្រុក ខណ្ឌ(២០៣) និងទី ៣)ឃុំ សង្កាត់(១៦៤៦)។ ថវិកាសម្រាប់រដ្ឋបាលនៅថ្នាក់ក្រោមជាតិស្មើនឹង ៨២២ លានដុល្លារ ក្នុងឆ្នាំ ២០២០(៥៦២ លានដុល្លារសម្រាប់រាជធានី ខេត្ត ៦១លានដុល្លារសម្រាប់ក្រុង ស្រុក ខណ្ឌ ១៩៨លានដុល្លារ សម្រាប់ឃុំ សង្កាត់)។ ថវិកា ឆ្នាំ ២០២០ កើនឡើង ៥១% បើធៀបនឹងថវិកាឆ្នាំ ២០១៩ ដែលមានចំនួន ៥៤៣ លានដុល្លារ។ ថវិកាថ្នាក់ក្រោមជាតិទទួលបានពី ៣ ប្រភពធំៗ÷ ទី ១)ចំណូលសារពើពន្ធ (៦៣%) ទី ២)ចំណូលមិនមែនសារពើពន្ធ(៥%) និងទី ៣) ការឧបត្ថម្ភពីថ្នាក់ជាតិ(៣២%) និងបែងចែកជាចំណាយ ៣ ប្រភេទធំៗ÷ ទី ១)បៀវត្សរ៍(១៨%) ទី ២)ចំណាយមូលធន (១៤%) និង ទី ៣)ចំណាយមិនមែនបុគ្គលិក (៦៨%)។ អាជ្ញាធរថ្នាក់ក្រោមជាតិមានសិទ្ធិគ្រោងថវិកាទៅតាមតម្រូវការក្នុងមូលដ្ឋានរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រស្តីពីការផ្តល់ហិរញ្ញប្បទានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**វាគ្មិន÷ លោក ជ័យ សម្បត្តិផល្លា ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)**

មុខងារសំខាន់មួយក្នុងចំណោមមុខងារសំខាន់ៗរបស់ គ.ជ.អ.ប. គឺរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការធ្វើប្រតិភូកម្មការផ្តល់សេវាសាធារណៈសំខាន់ៗដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់សេវាដល់ប្រជាពលរដ្ឋ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើវិភាជន៍ថវិកាដល់សាលាក្រុងនីមួយៗទៅតាមចំណូលប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ដោយសារធនធានមានកម្រិត ចំនួនថវិកាដែលវិភាជន៍សរុបដល់ថ្នាក់ខេត្ត និងថ្នាក់ឃុំ មានការឡើងចុះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ការកសាងសមត្ថភាពរដ្ឋបាលនៅថ្នាក់ស្រុក និងថ្នាក់ឃុំគឺជាបញ្ហាបន្ទាន់ចំពោះមុខដែលត្រូវធ្វើការដោះស្រាយ។

**វាគ្មិន÷ លោក Ajay Suri អ្នកគ្រប់គ្រងកម្មវិធីសម្ព័ន្ធភាពទីក្រុងក្នុងតំបន់អាស៊ី (Cities Alliance Asia)**

ភាពជាដៃគូរវាងរដ្ឋ និងឯកជនមិនអាចកើតឡើងដាច់ដោយឡែកតែឯងនោះឡើយ ប៉ុន្តែគួរមានការធ្វើវិមជ្ឈការប្រកបដោយប្រសិទ្ធភាព។ របៀបវារៈទីក្រុងថ្មី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងក្របខណ្ឌ Sendai សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលសុទ្ធតែជាក្របខណ្ឌកម្រិតសកលបានលើកឡើងថា អាជ្ញាធរមូលដ្ឋានមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍទីក្រុង និងសហគមន៍ប្រកបដោយចីរភាព និងភាពធន់។ ទីក្រុងនានា

កំពុងជួបប្រទះនឹងបញ្ហាប្រឈមពាក់ព័ន្ធនឹងការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាពដូចជាបញ្ហាប្រឈមពាក់ព័ន្ធនឹងយុត្តាធិការ មុខងារ និងភាពមិនស៊ីសង្វាក់គ្នានៃការបំពេញមុខងារ ហើយទន្ទឹមគ្នានេះទៀតសោតអាជ្ញាធរមូលដ្ឋានមានសមត្ថភាពនៅមានកម្រិតនៅឡើយ។ អ្វីដែលស្តែងចេញយ៉ាងច្បាស់នោះគឺគួរធ្វើការពិចារណាឡើងវិញពីប្រព័ន្ធពន្ធដារនៅក្នុងស្រុក និងភាពបត់បែនរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការប្រើប្រាស់ថវិកាដែលវិភាជន៍ពីរាជរដ្ឋាភិបាលថ្នាក់ជាតិ។

**វាគ្មិន÷ បណ្ឌិត តាន់ មុន្នីវណ្ណ អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា**

ការចូលរួមរបស់វិស័យឯកជនគឺជាគន្លឹះមួយដើម្បីសម្រេចសក្តានុពលនៃការអភិវឌ្ឍទីក្រុង។ ក្នុងប្រទេសកម្ពុជាមានសមាគមអាជីវកម្មសរុបចំនួន ១៨។ សមាគមធំៗចំនួន ២ រួមមាន÷ សមាគមសំណង់កម្ពុជា (CCA) និងសមាគមលំនៅឋានកម្ពុជា (CHA)។ សភាពាណិជ្ជកម្មកម្ពុជាធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាល។ ការរីកចម្រើនដ៏ខ្លាំងក្លានៃវិស័យសំណង់នៅកម្ពុជាកំពុងបង្កឱ្យមានបញ្ហាប្រឈមដូចជាកង្វះកម្លាំងពលកម្ម និងទុនសម្រាប់វិស័យសំណង់ជាដើម។ រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រព័ន្ធពន្ធដារ ដូចជាកាត់បន្ថយពន្ធសម្រាប់ក្រុមហ៊ុនសំណង់ក្នុងស្រុកជាដើម។ ថ្វីត្បិតមានគោលនយោបាយជាតិស្តីពីលំនៅឋានដែលមានតម្លៃសមរម្យ ប៉ុន្តែការអនុវត្តនៅមានកម្រិតនៅឡើយ។ ដូច្នេះគួរជំរុញឱ្យក្រុមហ៊ុនឯកជនចូលរួមបន្ថែមទៀតក្នុងកិច្ចពិគ្រោះយោបល់ស្តីពីអនាគតនៃទីក្រុង។

**អនុសាសន៍÷**

សម្រាប់ភាគីដែលធ្វើការពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងជាពិសេសអាជ្ញាធររដ្ឋាភិបាល ការកសាងភាពជាដៃគូជាមួយនឹងវិស័យឯកជនគឺជាគន្លឹះដើម្បីសម្រេចឱ្យបាននូវសក្តានុពលនៃការអភិវឌ្ឍទីក្រុងនៅក្នុងបរិបទកម្ពុជា។ ទីក្រុងកំពុងជួបប្រទះនឹងការលំបាកក្នុងការឈានទៅសម្រេចការអភិវឌ្ឍ



ប្រកបដោយចីរភាព ដោយសារតែធនធាននៅមានកម្រិត។ គួរមានការពិនិត្យ និងពង្រឹងប្រព័ន្ធពន្ធដារដើម្បីផ្តល់នូវបរិយាកាសអំណោយផលបន្ថែមទៀតដល់អាជ្ញាធរនៅថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួន។ គួរជំរុញឱ្យវិស័យឯកជនចូលរួមបន្ថែមនៅក្នុងកិច្ចពិគ្រោះយោបល់នៅកម្រិតគោលនយោបាយ។

## ២.៥. សេចក្តីថ្លែងការណ៍របស់យុវជន

មុននឹងឈានដល់វគ្គបញ្ចប់នៃវេទិកា យុវជននិងយុវតីចំនួន ៤ នាក់បានផ្តល់សេចក្តីថ្លែងការណ៍ខ្លីៗអំពីអ្វីដែលពួកគាត់ ចង់បានសម្រាប់ទីក្រុងរបស់ពួកគេរួមមាន÷

**យុវជន ជូ គីមស្រេង និស្សិតឆ្នាំទី ៤ មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី នៃសកលវិទ្យាល័យភូមិន្ទកសិកម្ម**

នគរូបនីយកម្មក្នុងប្រទេសកម្ពុជាគួរតែជាមាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពដោយគិតពីទិដ្ឋភាព សេដ្ឋ



កិច្ច សង្គម និងបរិស្ថាន។ លើសពីនេះទៅទៀតការអភិវឌ្ឍទីក្រុងគួរមានលទ្ធភាពក្នុងការផ្តល់សេវាកម្មមូលដ្ឋានដូចជា ការអប់រំ ការថែទាំសុខភាព ការកម្សាន្ត ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត អគ្គិសនី ផ្លូវថ្នល់ គមនាគមន៍ និងបច្ចេកវិទ្យា។

**យុវតី ជី សុជាតា សិស្សថ្នាក់ទី ១០ នៃវិទ្យាល័យជាស៊ីម ជ្រោយចង្វារ**

សុជាតា ចង់ឱ្យទីក្រុងស្អាត មានសុវត្ថិភាព និងបរិយាបន្ន។ យុវតីនេះបានស្នើឱ្យរាជរដ្ឋាភិបាលផ្តល់ការអប់រំដល់អ្នកដែលមិនយកចិត្តទុកដាក់ពីបរិស្ថាន និងកាត់បន្ថយឧក្រិដ្ឋកម្មក្នុងទីក្រុង។ ប្អូនស្រីក៏បានបន្ថែមទៀតថា ការអភិវឌ្ឍទីក្រុងគួរអាចផ្តល់អត្ថប្រយោជន៍សម្រាប់គ្រប់គ្នា។

**កុមារា និមិត្ត បញ្ញា សិស្សថ្នាក់ទី ៦ នៃសាលាបឋមសិក្សាព្រះនរោត្តម**







**បញ្ញា** ចង់ឱ្យមានសាលានៅគ្រប់ទីក្រុងទាំងអស់ មានគ្រូដែលពោរពេញដោយបទពិសោធន៍។ សាលាគួរតែឥតបង់ប្រាក់សម្រាប់សិស្សទាំងអស់។ ប្អូនប្រុសក៏ចង់ឱ្យមានគំនូសសញ្ញាលើផ្លូវសម្រាប់កុមារឆ្លងកាត់ផងដែរ។ ជាចុងក្រោយ បញ្ញាជឿជាក់ថាទីក្រុងដែលស្អាតគឺជាចំណុចដែលសំខាន់។

**យុវតី ថៃ ស្រីលីន សិស្សថ្នាក់ទី ១១ វិទ្យាល័យសម្តេចហ៊ុនសែនភ្នំពេញថ្មី**

ក្នុងនាមជាជនពិការ ស្រីលីនបានស្នើសុំឱ្យមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ជនពិការ។ ផ្លូវធ្វើដំណើរគួរមិនមែនជាឧបសគ្គអ្វីឡើយ។ លើសពីនេះទៅទៀតត្រូវបង្កើតសាលាសម្រាប់សិស្សដែលមានពិការភាព។ បញ្ហាបរិស្ថានគួរត្រូវ បានយកចិត្តទុកដាក់។ សម្រាប់ប្រជាជនទីតាមទីជនបទ ឬតំបន់ដែលដាច់ស្រយាល កម្មវិធីបណ្តុះបណ្តាល ឬសិក្ខាសាលាពីបញ្ហាបរិស្ថានចាំបាច់ត្រូវធ្វើ។ ការកាត់បន្ថយនៃការកកស្ទះចរាចរណ៍និងការបំពុលបរិស្ថានក្នុងរាជធានីភ្នំពេញគួរត្រូវ

ចាត់ទុកជាអាទិភាព។

## ២.៦. ជំហានបន្ទាប់ និងកម្មវិធីបិទ

វេទិកានេះបានបញ្ចប់ជាមួយនឹងការលើកឡើងពីអាទិភាពសំខាន់ៗ និងជំហានបន្ទាប់សម្រាប់កំណត់ចក្ខុវិស័យទីក្រុងនៅកម្ពុជា។

វាគ្មិននៅក្នុងកម្មវិធីនេះរួមមាន÷

- លោក Lars Stordal មន្ត្រីលេខាធិការដ្ឋានវេទិកាទីក្រុងពិភពលោករបស់អង្គការ UN-Habitat
- ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក
- ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
- លោកស្រី Pauline Tamesis អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា
- ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- អ្នកសម្របសម្រួល÷ លោក Sardar Umar Alam ប្រធានការិយាល័យនិងជាតំណាងយូណេស្កូប្រចាំកម្ពុជា

លោក Stordal បានបង្ហាញដោយសង្ខេបពីអនុសាសន៍សំខាន់ៗដែលត្រូវបានដាក់ចេញក្នុងវេទិកានេះ។ លោកបានបង្ហាញពីភាពចាំបាច់ដែលត្រូវរៀបចំគោលនយោបាយនិងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្តឱ្យបានរឹងមាំ ដើម្បីតម្រង់ទិសឱ្យបានកាន់តែប្រសើរដល់ការអភិវឌ្ឍទីក្រុង។ លោកបានលើកឡើងថាអ្នកចូលរួមជាច្រើនបានលើកឡើងពីភាពចាំបាច់ក្នុងការ





ធានានូវ “**ទីក្រុងសម្រាប់ទាំងអស់គ្នា**” ដោយធ្វើការពិចារណាអនុវត្តអភិក្រមដែលគិតគូរពីតម្រូវការរបស់ប្រជាជន។ លោកបានកត់សម្គាល់ថា ការអនុវត្តគោលនយោបាយទីក្រុងត្រូវការធនធាន និងការធ្វើសុខុដុមនីយកម្មតួនាទីរវាងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះភាពជាដៃគូមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីជំរុញឱ្យមានការអភិវឌ្ឍទីក្រុងដែលមានការគ្រប់គ្រងបានល្អ។ ការអភិវឌ្ឍទីក្រុងមិនអាចសម្រេចទៅបានឡើយប្រសិនបើពុំមានការចូលរួមពីវិស័យធុរកិច្ច។

ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** បានកត់សម្គាល់ថា នៅក្នុងវេទិកានេះមានការគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការរៀបចំគោលនយោបាយដែលជាឧបករណ៍ដ៏សំខាន់នៅពេលដែលធ្វើការពិភាក្សាពីការអភិវឌ្ឍទីក្រុង។ អ្នកតាក់តែងគោលនយោបាយចាំបាច់ត្រូវយល់ពីស្ថានភាពរបស់ប្រជាជន និងស្ថានភាពរបស់ទីក្រុង។

លោកស្រី Tamesis បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការចាត់វិធានការ និងធានាឱ្យមានការអនុវត្តសកម្មភាពបន្តពីវេទិកានេះ។ លោកស្រីបានបន្តថា អភិក្រមដែលគិតគូរពីតម្រូវការរបស់ប្រជាជន និងភាពចាំបាច់ក្នុងការស្តាប់ការព្រួយបារម្ភនានារបស់ប្រជាជនដើម្បីធានាយ៉ាងណាឱ្យសេវាកម្មនានាពិតជាបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន។

ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** បានគូសបញ្ជាក់ឡើងវិញថា ប្រជាជាតិកម្ពុជាទាំងមូលកំពុងរស់នៅក្នុងសុខសន្តិភាព ឯកភាពជាតិនិងទឹកដី ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាល



ទី៤ ត្រង់ចតុកោណទី៤ បានកំណត់អំពីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន និងការពង្រឹងការគ្រប់គ្រងនគរូបនីយកម្មតាមរយៈការអភិវឌ្ឍទីក្រុងឱ្យមានបរិស្ថានល្អសម្រាប់ការរស់នៅ គុណភាព សុវត្ថិភាព សោភណភាព សុខុមាលភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច- សង្គមស្របតាមគោលការណ៍ទីក្រុងឆ្លាតវៃក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្នតាមរយៈការជំរុញការអភិវឌ្ឍ និងការពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្ត ដោយផ្សារភ្ជាប់យុទ្ធសាស្ត្រសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទីក្រុងជាមួយការអនុវត្តនិងការអភិវឌ្ឍនគរូបនីយកម្ម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ការអភិវឌ្ឍទីក្រុងតម្រូវឱ្យមានការចូលរួមប្តេជ្ញាចិត្តពីវិស័យនានាមានជាអាទិ៍វិស័យរៀបចំដែនដី នគរូបនីយកម្ម បរិស្ថាន វប្បធម៌ សាធារណការ សេដ្ឋកិច្ច សង្គម។ល។ ការអភិវឌ្ឍដោយបរិយាបន្នមានន័យថាជាការអភិវឌ្ឍសម្រាប់ទាំងអស់គ្នាពោលគឺមិនទុកនរណាម្នាក់ចោល។ វេទិកានេះត្រូវបាន ធ្វើឡើងនៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលបាន ផ្តល់នូវកាលានុវត្តភាពយ៉ាងច្រើនដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជាក្នុងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ពន្លឿនការអភិវឌ្ឍប្រទេសយ៉ាងឆាប់រហ័សតាមរយៈផលិតកម្មផ្អែកលើប្រព័ន្ធឌីជីថលនិងបញ្ញាសិប្បនិម្មិតក្នុងការបង្កើនផលិតភាពប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព និងភាពប្រកួតប្រជែង។ អង្គវេទិកាបានទទួលស្គាល់ថា “**អភិក្រមនគរូបនីយកម្ម**” នឹងកាន់តែមានប្រសិទ្ធភាពតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ ការជំរុញការចូលរួមគាំទ្រ ការពង្រឹងចំណេះដឹងការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដី គោលនយោបាយជាតិស្តីពីលំនៅឋាន និងការ

ស្វែងរកដំណោះស្រាយរួមគ្នាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានាដើម្បីបង្កើតភាពជាដៃគូដោយផ្ដោតលើការអនុវត្តសកម្មភាពជាក់ស្ដែងនៅគ្រប់កម្រិតទាំងអស់។ ទន្ទឹមជាមួយគ្នានេះ វេទិកានគរូបនីយកម្មកម្ពុជាលើកទី១ ពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍទីក្រុងនាពេលអនាគតដោយយកចិត្តទុកដាក់លើតម្រូវការនិងការចូលរួមរបស់ប្រជាពលរដ្ឋដើម្បីនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមានដល់ទីក្រុង និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋដើម្បីសម្រេចឱ្យបាននូវវិបុលភាពរយៈពេលវែងនៅព្រះរាជាណាចក្រកម្ពុជា។ វេទិកានេះ ពិតជាមានសារៈសំខាន់ផងដែរក្នុងការជំរុញឱ្យទីក្រុងរបស់កម្ពុជាក្លាយជាតំបន់ស្នូលនៃកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពសំដៅធានាបាននូវម៉ាក្រូសេដ្ឋកិច្ចរឹងមាំបន្តទៀត និងឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឈានឡើងទៅជាប្រទេសមានចំ ណូលខ្ពស់នៅឆ្នាំ ២០៥០។

**អនុសាសន៍÷**

ការចាត់វិធានការដោយប្រើប្រាស់អភិក្រមដែលគិតគូរពីតម្រូវការរបស់ប្រជាជនមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីនានា។ ការរៀបចំគោលនយោបាយជាតិ និងក្របខណ្ឌគតិយុត្តដែលមានភាពច្បាស់លាស់គឺជាគន្លឹះដ៏សំខាន់។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិគួរពិនិត្យតាមដានដើម្បីឱ្យមានការបន្តកិច្ចពិគ្រោះយោបល់បន្ទាប់ពីវេទិកានេះ។ ស្របតាមរបៀបវារៈអភិវឌ្ឍន៍សកល និងក្របខណ្ឌអភិវឌ្ឍន៍ទីក្រុង វេទិកានេះនឹងបន្តស្ដាប់សម្លេងរបស់ប្រជាជន និងស្វែងរកដំណោះស្រាយដើម្បីកសាងទីក្រុងឆ្លាតវៃប្រកបដោយចីរភាព និងបរិយាបន្នសម្រាប់ទាំងអស់គ្នានៅកម្ពុជា។

# ៣

# សេចក្តីប្រកាសនៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

សេចក្តីប្រកាសនៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ ស្តីពីការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្នសម្រាប់ជួយគាំទ្រដល់យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ត្រូវបានអនុម័តដោយភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងវេទិកានេះ ដូចមានបង្ហាញលំអិតខាងក្រោមដែលឆ្លុះបញ្ចាំងពីអាទិភាពសំខាន់ៗ និងអនុសាសន៍សម្រាប់យកទៅអនុវត្តដើម្បីឈានទៅសម្រេចគោលដៅ។

**វេទិកានគរូបនីយកម្មកម្ពុជាលើកទី ១**
**ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៩ រាជធានីភ្នំពេញ**
**ប្រទេសកម្ពុជា**

**សេចក្តីប្រកាស**
**ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព**
**និងបរិយាបន្ន**

**យើងទាំងអស់គ្នា**ដែលជាអ្នកចូលរួមក្នុងវេទិកានគរូបនីយកម្មកម្ពុជា (CUF) លើកទី ១ ដែលបានសហការរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បានជួបប្រជុំគ្នាក្រោមប្រធានបទ “**ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន**” នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៩។

ដើម្បីបង្កើនប្រសិទ្ធភាពនៃវេទិកាដែលធ្វើឡើងដោយមានលក្ខណៈបរិយាបន្ននេះ យើងបានព្រមព្រៀងគ្នាក្នុងការកែសម្រួលនិងកំណត់ចក្ខុវិស័យដូចខាងក្រោមដើម្បីឈានទៅការអភិវឌ្ឍទីក្រុងក្នុងប្រទេសកម្ពុជាឱ្យកាន់តែប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន ស្របតាមមុំទី ៣ នៃចតុកោណទី ៤ ដែលបានកំណត់អំពីការពង្រឹងការគ្រប់គ្រងនគរូបនីយកម្មដែលមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០÷



*ទីក្រុងនាពេលអនាគតដែលមានចីរភាព និងផ្តោតការយកចិត្តទុកដាក់លើតម្រូវការ និងការចូលរួមរបស់ប្រជាជនមានសារៈសំខាន់ក្នុងការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានដល់ទីក្រុង និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋដើម្បីសម្រេចឱ្យបាននូវវិបុលភាពរយៈពេលវែងនៅប្រទេសកម្ពុជា។ ជាការសំខាន់ណាស់ដែលត្រូវផ្តោតការយកចិត្តទុកដាក់ជាថ្មីលើការកសាងភាពជាដៃគូរវាងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ រដ្ឋបាលនៅថ្នាក់ក្រោមជាតិ វិស័យឯកជន និងសង្គមស៊ីវិលសំដៅរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងអភិបាលកិច្ចប្រកបដោយបរិយាបន្នក្នុងទីក្រុង ហើយក្នុងពេលជាមួយគ្នាលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងធានាបាននូវចីរភាពបរិស្ថាន។ ក្នុងការសម្រេចចក្ខុវិស័យនេះការដាក់ចេញនូវគោលនយោបាយ និងច្បាប់ដែលមានភាពជឿនលឿន យន្តការផ្តល់ហិរញ្ញប្បទានដែលមានលក្ខណៈច្នៃប្រឌិតថ្មី ការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយភាពឆ្លាតវៃនិងចីរភាព ព្រមទាំងការជំរុញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្តគឺជាកត្តាសំខាន់ដែលជួយឱ្យមានការកសាងនូវទីក្រុងដែលមានបរិយាបន្ន សុវត្ថិភាព ភាពធន់ និងចីរភាពនៅក្នុងប្រទេសកម្ពុជា។*

**ក. វឌ្ឍនភាពដែលសម្រេចបានកន្លងមក និងកិច្ចព្រមព្រៀងនាពេលបច្ចុប្បន្នដែលផ្តល់ការតម្រង់ទិសដល់ការចូលរួមសហការរបស់យើង÷**

១. គូសបញ្ជាក់សាជាថ្មីពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់ប្រទេសកម្ពុជាក្នុងការសម្រេចគោលដៅការអភិវឌ្ឍប្រកបដោយចីរភាព ការធ្វើជាតិតូបនីយកម្ម និងមូលដ្ឋានីយកម្មគោលដៅទាំងនេះដើម្បីបង្កើតបានជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាដូចដែលត្រូវបានដាក់ចេញក្នុងរបាយការណ៍ស្តីពីការពិនិត្យឡើងវិញដោយស្ម័គ្រចិត្តថ្នាក់ជាតិលើកទី ១ ដែលត្រូវបានបង្ហាញនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៩។

២. គូសបញ្ជាក់សាជាថ្មីពីតួនាទីដ៏សំខាន់នៃនគរូបនីយកម្មក្នុងនាមជាកត្តាពន្លឿនការអភិវឌ្ឍប្រកបដោយចីរភាព ដូចដែលត្រូវបានឆ្លុះបញ្ចាំងក្នុងការអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១១ និងរបៀបវារៈទីក្រុងថ្មី និងទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមដ៏មានខ្លឹមសាររបស់ភាគីពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការ និងដំណើរការនៃការតាមដានបន្ត (កថាខណ្ឌ ៤១ នៃរបៀបវារៈទីក្រុងថ្មី) និងការកសាងភាពជាដៃគូរវាងស្ថាប័នដ៏មានប្រសិទ្ធភាពរវាងរដ្ឋបាលនៅគ្រប់កម្រិត អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា (កថាខណ្ឌទី ៩២ នៃរបៀបវារៈទីក្រុងថ្មី)។

៣. កត់សម្គាល់ថា កិច្ចប្រជុំមុនថ្ងៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ នេះជាមួយនឹងស្ថាប័នពាក់ព័ន្ធជាច្រើនត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជាកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដែលបានផ្តល់អនុសាសន៍ឱ្យមានការដាក់ចេញនូវសេចក្តីប្រកាសនេះ ដែលនឹងបង្ហាញពីចំណុចអាទិភាព និងវិធានការដែលត្រូវអនុវត្តដើម្បីឱ្យមានការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ននៅកម្ពុជា។

**ខ. បញ្ហាអាទិភាព និងលទ្ធផលដែលត្រូវបានកំណត់ចេញពីអ្នកចូលរួមក្នុងវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១**

១. ជាមួយនឹងការកត់សម្គាល់ដោយយោងតាមទិន្នន័យផ្លូវការបានឱ្យឃើញថា ចំនួនប្រជាជនក្នុងទីក្រុងនៅកម្ពុជានឹងកើនឡើងទ្វេដងត្រឹមឆ្នាំ ២០៥០ ច្រើនជាង ៩ លាននាក់ ឬស្មើនឹង ៤១,២% នៃ

ចំនួនប្រជាជនសរុបដែលនាំឱ្យមានកំណើនតម្រូវការហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលផ្តល់ភាពងាយស្រួលដល់ប្រជាជនក្នុងការប្រើប្រាស់ធនធានធម្មជាតិ ដីធ្លី និងសេវាជាមូលដ្ឋាននានា។

២. ទទួលស្គាល់ថា នគរូបនីយកម្មគឺជាកម្លាំងវិជ្ជមានដ៏មានអានុភាពក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ប្រសិនបើមានការធ្វើផែនការ និងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ហើយការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងទីក្រុងរបស់ប្រទេសកម្ពុជាក៏ជាកាលានុវត្តភាពមួយសម្រាប់អនុវត្តចក្ខុវិស័យសម្លឹងទៅមុខ ក្រោមការដឹកនាំដ៏ត្រឹមត្រូវដើម្បីសម្រេចឱ្យបាននូវអនាគតប្រកបដោយវិបុលភាពសម្រាប់ប្រជាជនគ្រប់រូប។

៣. ប៉ុន្តែនៅមានមានការព្រួយបារម្ភដែរថាការអភិវឌ្ឍទីក្រុងដ៏ឆាប់រហ័សដោយមិនមានផែនការទុកជាមុន កំពុងនាំឱ្យមានការកើនឡើងនូវបញ្ហាតាំងទីលំនៅឋានក្រៅផ្លូវការនៅក្នុងតំបន់ទីក្រុង និងតំបន់ជាយក្រុង ដែលនាំឱ្យស្ថានភាពលំនៅឋានមានភាពអន់ខ្សោយ ការបំពុលបរិស្ថានក្នុងតំបន់ ការកកស្ទះចរាចរណ៍ កង្វះហេដ្ឋារចនាសម្ព័ន្ធ កង្វះសេវាមូលដ្ឋាននៅក្នុងទីក្រុង ភាពងាយរងគ្រោះដោយសារកត្តាអាកាសធាតុ និងការធ្វើការងារក្នុងវិស័យក្រៅប្រព័ន្ធដែលមានលក្ខខណ្ឌលំបាក។

៤. ទទួលស្គាល់ថា គោលនយោបាយជាតិស្តីពីនគរូបនីយកម្មចាំបាច់ត្រូវពិចារណាលើទំនាក់ទំនងដ៏ជិតស្និទ្ធនៃការធ្វើចំណាកស្រុក និងនគរូបនីយកម្ម ព្រមទាំងតួនាទីដ៏សំខាន់នៃទីក្រុងក្នុងការគ្រប់គ្រងការផ្លាស់ទីរបស់ប្រជាជន។

៥. ប្តេជ្ញាធានានូវការធ្វើនគរូបនីយកម្មដែលគិតគូរដល់ប្រជាជនជាចំបងដោយទទួលស្គាល់តួនាទីរបស់ស្ត្រី យុវជន និងប្រជាជនគ្រប់រូបដោយមិនគិតពីឋានៈ សេដ្ឋកិច្ច សង្គម ក្នុងការចូលរួមចំណែកដើម្បីបង្កើតទីក្រុងដែលមានលក្ខណៈបរិយាបន្នគួរឱ្យចង់រស់នៅ មានសុវត្ថិភាព និងមានវិបុលភាព។

៦. ទទួលស្គាល់ថាសិទ្ធិប្រើប្រាស់ដីធ្លីនិងអភិបាលកិច្ចដីធ្លីមានឥទ្ធិពលយ៉ាងធំធេងលើនគរូបនីយកម្ម និងទទួលស្គាល់ថា ការខ្វះសិទ្ធិ និងអភិបាលកិច្ចខាងលើនេះជាកត្តាបន្ថយបង្អាក់ដល់លទ្ធភាពនៃទីក្រុង និងទីប្រជុំជននានាក្នុងការរីកចម្រើន។ ភាពជាម្ចាស់របស់សហគមន៍ក្នុងគម្រោងអភិវឌ្ឍន៍ជាគន្លឹះដែលមាននិរន្តរភាពយូរអង្វែង និងវិបុលភាព។

៧. គូសបញ្ជាក់សាជាថ្មីថា ការបញ្ចូលវិធីសាស្ត្រដែលផ្តោតសំខាន់លើប្រជាជនក្នុងការរៀបចំផែនការទីក្រុង រួមមានការយកចិត្តទុកដាក់លើការប្រើប្រាស់ដីក្នុងគោលបំណងរួម លំហសាធារណៈដែលមានលក្ខណៈបរិយាបន្ន ការថែរក្សាសម្បត្តិវប្បធម៌ដូចជាការរចនាទីក្រុងប្រកបដោយចីរភាព មានវិធានការសុវត្ថិភាព និងការធ្វើសមាហរណកម្មទីផ្សារដីធ្លី។

៨. គូសបញ្ជាក់សាជាថ្មីថា កង្វះការទទួលបានលំនៅឋានមានតម្លៃសមរម្យនៅតែជាបញ្ហាប្រឈម និងការផ្តល់ជាជម្រើសលំនៅឋានផ្សេងៗដែលសមរម្យសម្រាប់ក្រុមដែលមានចំណូលទាបដែលជាចំណុចអាទិភាព និងត្រូវការគំរូហិរញ្ញប្បទានថ្មី និងការសហការជាមួយនឹងវិស័យឯកជន។

៩. ទទួលស្គាល់ពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការនៃការធ្វើផែនការដើម្បីធានាភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងវិបត្តិដោយសារគ្រោះថ្នាក់ធម្មជាតិ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងកត្តាផ្សេងៗទៀតក្នុងការការពារបរិស្ថានធម្មជាតិ និងការអភិវឌ្ឍបៃតង។

១០. ទាញប្រយោជន៍ពីបច្ចេកវិទ្យាទីក្រុងឆ្លាតវៃមកប្រើប្រាស់ក្នុងការគាំទ្រចក្ខុវិស័យឆ្ពោះទៅរកការអភិវឌ្ឍទីក្រុងដែលមានលក្ខណៈបរិយាបន្ន និងផ្តោតការយកចិត្តលើប្រជាជនក្នុងប្រទេសកម្ពុជាដោយប្រើប្រាស់បច្ចេកវិទ្យាទាំងនោះដើម្បីជួយក្នុងការប្រមូលទិន្នន័យ និងប្រើប្រាស់ទិន្នន័យទីក្រុងដែលត្រឹមត្រូវសម្រាប់ការធ្វើផែនការនិងការគ្រប់គ្រងទីក្រុង។

១១. ទទួលស្គាល់ថា អភិក្រមនគរូបនីយកម្មនឹងកាន់តែមានប្រសិទ្ធភាពតាមរយៈការចូលរួមកសាងចំណេះដឹង និងដំណោះស្រាយរួមគ្នាជាមួយនឹងភាគីពាក់ព័ន្ធចម្រុះ ហើយការលើកកម្ពស់ការបង្កើតនូវភាពជាដៃគូដែលផ្តោតលើការធ្វើសកម្មភាពជាក់ស្តែងនៅគ្រប់កម្រិតទាំងអស់ ជាពិសេសជាមួយនឹងវិស័យឯកជន។

១២. គូសបញ្ជាក់សាជាថ្មីពីតម្រូវការសម្រាប់គោលនយោបាយជាតិស្តីពីនគរូបនីយកម្មដែលមានបរិយាបន្ន អាចអនុវត្តបាន និងមានការចូលរួមក្រោមការកែសម្រួល និងគាំទ្រពីក្របខណ្ឌស្ថាប័ន និងគតិយុត្តពីគ្រប់កម្រិតទាំងអស់របស់រាជរដ្ឋាភិបាល និងប្តេជ្ញាអភិវឌ្ឍលើគោលនយោបាយជាតិស្តីពីនគរូបនីយកម្ម និងគោលនយោបាយជាតិស្តីពីលំនៅឋានសម្រាប់ប្រទេសកម្ពុជាដោយទាញយកប្រយោជន៍ពីវេទិកាដែលមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះដូចជាវេទិកានគរូបនីយកម្មកម្ពុជានេះជាដើម។

## គ. អនុសាសន៍÷

ផ្អែកតាមអាទិភាព និងលទ្ធផលដូចលើកឡើងខាងលើវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១ ប្តេជ្ញា÷

១. ផ្តល់ការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងចក្ខុវិស័យឆ្នាំ ២០៥០ របស់ប្រទេសកម្ពុជាដោយគាំទ្រឱ្យមានការដាក់ចេញនូវចក្ខុវិស័យនគរូបនីយកម្មប្រកបដោយចីរភាពដែលទីក្រុង និងកន្លែងតាំងទីលំនៅរបស់មនុស្សគ្រប់រូបភាពនឹងមានវិបុលភាព បរិយាបន្ន សុវត្ថិភាព ឆ្លាតវៃ និងចីរភាពស្របតាមប្រវត្តិសាស្ត្រ គុណតម្លៃ និងបរិបទរបស់ប្រទេស។

២. ធ្វើការងារដើម្បីកសាងនូវមូលដ្ឋានចំណេះដឹងឱ្យកាន់តែរឹងមាំ និងប្រើប្រាស់ភស្តុតាងសម្រាប់ការតាក់តែងគោលនយោបាយជាតិស្តីពីនគរូបនីយកម្មរួមមានការប្រមូលនិងវិភាគទិន្នន័យក្នុងទម្រង់ថ្មីៗ និងមានការច្នៃប្រឌិតដើម្បីផ្តល់ព័ត៌មានសម្រាប់ធ្វើផែនការ និងការសម្រេចចិត្តអំពីការវិនិយោគនានា។

៣. បង្កើនចំណេះដឹងដល់ភាគីពាក់ព័ន្ធទាំងអស់ទាំងក្នុងវិស័យរដ្ឋ និងឯកជនអំពីភាពចាំបាច់ក្នុងការបង្កើនការវិនិយោគរយៈពេលវែងដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និងការផ្តល់ហិរញ្ញប្បទានដែលអាចព្យាករដឹងមុនបានដល់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាពដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមធំៗនៅក្នុងទីក្រុងជាទ្រង់ទ្រាយធំ។

៤. គាំទ្រដល់ការកសាងនូវសន្ទះនៃបរិស្ថានដែលអំណោយផលថ្នាក់ជាតិដើម្បីការធ្វើនគរូបនីយកម្មប្រកបដោយចីរភាពតាមរយៈការដាក់ចេញនូវគោលនយោបាយជាតិស្តីពីនគរូបនីយកម្មនិងលំនៅឋានក្នុងទីក្រុង និងផែនការតាមវិស័យប្រកបដោយប្រសិទ្ធភាព ព្រមទាំងកិច្ចពិគ្រោះយោបល់បន្តបន្ទាប់ពីគ្រប់ស្ថាប័នដើម្បីពិនិត្យឡើងវិញ។

៥. ធានាឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងទីក្រុងនៅក្នុងដំណើរការនៃការរៀបចំគោលនយោបាយ និងការធ្វើផែនការដើម្បីបង្កើតទីក្រុងដែលផ្តោតសំខាន់លើប្រជាជននាពេលអនាគត។

## ឧបសម្ព័ន្ធទី ១: របៀបវារៈវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

| | |
|---|---|
| ០៨:០០–០៨:៣០ | ចុះឈ្មោះ |
| ៨:៣០ - ៨:៤០ | **របៀបវារៈទី ១÷ ពិធីបើកវេទិកា** |
| | ប្រកាសហេតុ វត្តបំណងនៃវេទិកា និងគោរពភ្លេងជាតិ<br>លោក **ម៉ុល វិបុល** - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៨:៤០ - ៨:៥០ | សុន្ទរកថាស្វាគមន៍<br>លោកស្រី Pauline Tamesis អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| ៨:៥០ - ៩:០៥ | បទអន្តរាគមន៍គន្លឹះ÷ ការអភិវឌ្ឍទីក្រុងឆ្លាតវៃប្រកបដោយចីរភាព និងមានបរិយាបន្ន លោកស្រី Gabriella Gomez-Mont ប្រធានក្រុមការងារអភិវឌ្ឍន៍ទីក្រុង និងជាអតីតប្រធានផ្នែកគំនិតច្នៃប្រឌិតរបស់ទីក្រុងម៉ិកស៊ិក្ក |
| ៩:០៥ - ៩:២០ | បទអន្តរាគមន៍គន្លឹះ÷ បទពិសោធន៍ពីប្រទេសកូរ៉េអំពីការអភិវឌ្ឍទីក្រុងដែលមានលក្ខណៈឆ្លាតវៃ និងចីរភាព<br>បណ្ឌិត Kim Kyunghwan សាស្ត្រាចារ្យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Sogang University និងជាអតីតរដ្ឋមន្ត្រីស្តីទីក្រសួងដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍នៃប្រទេសកូរ៉េ |
| ៩:២០ - ៩:៤០ | សុន្ទរកថាបើក<br>ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៩:៤០ - ១០:០០ | សម្រាក |
| | **របៀបវារៈទី ២÷ ទិដ្ឋភាពទូទៅអំពីនគរូបនីយកម្ម និងការអភិវឌ្ឍទីក្រុង÷ ស្ថានភាព បញ្ហាប្រឈម និងកាលានុវត្តភាព** |
| | អ្នកសម្របសម្រួល÷ លោក Laxman Perera មន្ត្រីលំនៅឋានមនុស្សជាតិ នៃការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក កម្មវិធីលំនៅឋានមនុស្សជាតិរបស់អង្គការសហប្រជាជាតិ |
| ១០:០០-១២:០០ | **“ប្រព័ន្ធនគរូបនីយកម្មនៅកម្ពុជា”**<br>ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម នឹងសំណង់ |
| | **“បញ្ហាប្រឈម និងឱកាសរបស់ទីក្រុងដើម្បីសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍សកលឆ្នាំ២០៣០”**<br>បណ្ឌិត Stefanos Fotiou នាយកផ្នែកបរិស្ថាន និងការអភិវឌ្ឍនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការ សហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| | **“ទីក្រុងសម្រាប់ទាំងអស់គ្នា÷ ហេតុអ្វីបានជាទីក្រុងចាំបាច់ត្រូវមានបរិយាបន្ន ភាពធន់ និងប្រកបដោយចីរភាព?”**<br>**បណ្ឌិត Frank Rijsberman អគ្គនាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល** |
| | សម្លេងប្រជាពលរដ្ឋ<br>លោកស្រី **គួ ស៊ីណា** ប្រធានកម្មវិធីអភិវឌ្ឍន៍ទីក្រុងសម្រាប់ស្ត្រីក្រីក្រ (មតិរបស់ភាគីពាក់ព័ន្ធពីកិច្ចប្រជុំមុនវេទិកា) |
| | កិច្ចពិភាក្សា សំណួរ និងចម្លើយ |
| ១២:០០-១៣:០០ | សម្រាកទទួលទានអាហារថ្ងៃត្រង់ |

| | |
|---|---|
| ១៣:០០-១៤:៣០ | របៀបវារៈទី ៣÷ ការកំណត់ពីអាទិភាពទីក្រុងរបស់ប្រទេសកម្ពុជា ÷<br>ការជំរុញលើកកម្ពស់គោលនយោបាយ និងការ សម្រេចឱ្យបាននូវទីក្រុងប្រកបដោយចីរភាព |
| | អ្នកសម្របសម្រួល÷ លោកស្រី Kristin PARCO ប្រធានបេសកកម្មអង្គការ IOM ប្រចាំប្រទេសកម្ពុជា |
| | **“អាទិភាព និងតម្រូវការចាំបាច់របស់រាជធានីភ្នំពេញក្នុងការប្រែក្លាយជាទីក្រុងដែលមានបរិយាបន្ន មានភាពធន់ និងប្រកបដោយចីរភាពពេញលក្ខណៈសម្រាប់ទាំងអស់គ្នា”**<br>ឯកឧត្តម **ស៊ុយ សេរិទ្ធ** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ |
| | **“អាទិភាពសម្រាប់ការអភិវឌ្ឍនគរូបនីយកម្មនៅកម្ពុជា”**<br>លោក **តាំង ម៉េងអៀង** ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយ ចីរភាព នៃក្រសួងបរិស្ថាន |
| | **“ការរចនាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការរៀបចំផែនការសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព”**<br>លោកស្រី Sandrine Capelle ប្រធានគ្រប់គ្រងពហុការិយាល័យអង្គការ UNOPS |
| | **របៀបវារៈទី ៤÷ ការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង** |
| | **អ្នកសម្របសម្រួល÷ លោក ហ៊ាង ផាត អ្នកឯកទេសនៃកម្មវិធីអភិវឌ្ឍន៍ទីក្រុងនៃមូលនិធិអង្គការសហប្រជាជាតិដើម្បីកម្ពុជា** |
| ១៤:៣០-១៥:៤៥ | **“ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិរបស់កម្ពុជា÷ តើប្រព័ន្ធនេះរួមចំណែកអ្វីខ្លះដល់ការផ្តល់ហិរញ្ញប្បទានក្នុងការអភិវឌ្ឍ ទីក្រុង?”**<br>លោក **ហួយ វិចិត្រ** តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | **“បញ្ហាប្រឈមនិងទស្សនៈវិស័យនាពេលអនាគតលើការអនុវត្តប្រព័ន្ធហិរញ្ញវត្ថុវិមជ្ឈការនៅថ្នាក់ក្រោមជាតិនៅ កម្ពុជា”**<br>**លោក ជ័យ សម្បត្តិផល្លា** ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| | **“ភាពជាដៃគូរវាងរដ្ឋ និងឯកជន÷ ការរួមចំណែក និងតម្រូវការរបស់វិស័យឯកជនក្នុងការអភិវឌ្ឍទីក្រុង”**<br>លោក Ajay Suri អ្នកគ្រប់គ្រងកម្មវិធីសម្ព័ន្ធភាពទីក្រុងក្នុងតំបន់អាស៊ី |
| | **“ការរួមចំណែក និងតម្រូវការរបស់វិស័យឯកជនក្នុងការអភិវឌ្ឍទីក្រុង”**<br>បណ្ឌិត **តាន់ មុន្នីវណ្ណ** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា |
| | កិច្ចពិភាក្សា សំណួរ និងចម្លើយ |
| ១៥:៤៥-១៦:០០ | សម្រាក |

| | |
|---|---|
| | **របៀបវារៈទី ៥÷ ជំហានបន្ទាប់ និងពិធីបិទវេទិកា** |
| | អ្នកសម្របសម្រួល÷ លោក Sardar Umar Alam ប្រធានការិយាល័យ<br>និងជាតំណាងយូណេស្កូប្រចាំកម្ពុជា |
| ១៦:០០-១៦:១០ | ចំណាប់អារម្មណ៍ស្តីពីការអភិវឌ្ឍទីក្រុងដោយ **និស្សិត សិស្ស និងកុមារ** (**៣នាទី/ម្នាក់**)<br>**១.** លោក **ជូ គឹមស្រេង** និស្សិតឆ្នាំទី ៤ មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លីនៃសកលវិទ្យាល័យភូមិន្ទ កសិកម្ម និងនិស្សិតឆ្នាំទី ២ ដេប៉ាតឺម៉ង់ភាសាអង់គ្លេសនៃវិទ្យាស្ថានភាសាបរទេសនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>**២.** កញ្ញា **ជី សុជាតា** សិស្សថ្នាក់ទី ១០ នៃសាលាវិទ្យាល័យជាស៊ីមជ្រោយចង្វារ<br>**៣.** កុមារា **និមិត្ត បញ្ញា** សិស្សថ្នាក់ទី ៦ នៃសាលាបឋមសិក្សាព្រះនរោត្តម<br>**៤.** កញ្ញា **ថៃ ស្រីលីន** សិស្សថ្នាក់ទី ១១ នៃសាលាវិទ្យាល័យសម្តេចហ៊ុនសែនភ្នំពេញថ្មី |
| ១៦:១០–១៦:៤០ | កិច្ចពិភាក្សារួមផ្តោតលើសារៈសំខាន់នៃសកម្មភាពដែលត្រូវអនុវត្តបន្ត ជំហានបន្ទាប់<br>លោក Lars Stordal មន្រ្តីលេខាធិការដ្ឋានវេទិកាទីក្រុងពិភពលោករបស់អង្គការ UN-Ha bitat ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| ១៦:៤០-១៦:៥០ | ការបូកសរុបលទ្ធផលវេទិកា÷ គូសបញ្ជាក់ពីអាទិភាពដែលបានឯកភាពគ្នា<br>និងសកម្មភាពដែលត្រូវអនុវត្តនៅ ដំណាក់កាលបន្ទាប់<br>ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិង<br>នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១៦:៥០–១៧:០០ | សុន្ទរកថាបិទ<br>ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

## ឧបសម្ព័ន្ធទី ២: បញ្ជីឈ្មោះអ្នកចូលរួមវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១

| ល.រ. | ស្ថាប័ន | ចំនួនអ្នកចូលរួម |
|---|---|---|
| ក. ក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល | | |
| ១ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១៥ |
| ២ | ក្រសួងកិច្ចការនារី | ១ |
| ៣ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ |
| ៤ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ |
| ៦ | ក្រសួងបរិស្ថាន | ៤ |
| ៧ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព | ២ |
| ៨ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ |
| ៩ | ក្រសួងផែនការ | ១ |
| ១០ | ក្រសួងការពារជាតិ | ១ |
| ១១ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ |
| ១២ | ក្រសួងយុត្តិធម៌ | ១ |
| ១៣ | ក្រសួងរ៉ែ និងថាមពល | ១ |
| ១៤ | ក្រសួងអប់រំ យុវជន និងកីឡា | ១ |
| ១៥ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ |
| ១៦ | ក្រសួងពាណិជ្ជកម្ម | ១ |
| ១៧ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ |
| ១៨ | ក្រសួងមុខងារសាធារណៈ | ១ |
| ១៩ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១ |
| | សរុបរង | ៣៨ |
| ខ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | | ២៥ |
| គ. រដ្ឋបាលរាជធានី ខេត្ត | | ២៥ |
| ឃ. អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ | | |
| ១ | UN Resident Coordinator Office | ១ |
| ២ | UNICEF | ១ |
| ៣ | UN Habitat | ៦ |
| ៤ | UNESCO | ៥ |
| ៥ | IOM | ២ |

| | | |
|---|---|---|
| ៦ | UNDP | ១ |
| ៧ | UNFPA | ១ |
| ៨ | UNFPA/UNYAP | ១ |
| ៩ | ILO | ១ |
| ១០ | WHO | ១ |
| ១១ | UNOPS | ៣ |
| ១២ | UNESCAP | ១ |
| ១៣ | UNIDO | ៣ |
| ១៤ | WFP | ១ |
| ១៥ | UNAIDS | ១ |
| ១៦ | UNOHCHR | ២ |
| ១៧ | Asian Development Bank (ADB) | ២ |
| ១៨ | EU | ១ |
| ១៩ | JICA | ១ |
| ២០ | Korea Exim Bank | ១ |
| ២១ | Korea Exim Bank | ១ |
| ២២ | KfW | ១ |
| ២៣ | USAID | ១ |
| | សរុបរង | ៣៩ |
| ង. ស្ថានទូត | | |
| ១ | ស្ថានទូតជប៉ុន | ១ |
| ២ | ស្ថានទូតអាល្លឺម៉ង់ | ១ |
| ៣ | ស្ថានទូតស៊ុយអែត | ១ |
| ៤ | ស្ថានទូតកូរ៉េខាងត្បូង | ១ |
| ៥ | ស្ថានទូតអូស្ត្រាលី | ១ |
| ៦ | ស្ថានទូតបារាំង | ១ |
| ៧ | ស្ថានទូតឥណ្ឌា | ១ |
| ៨ | ស្ថានទូតរុស្ស៊ី | ១ |
| ៩ | ស្ថានទូតសិង្ហបុរី | ១ |

| | | |
|---|---|---|
| | សរុបរង | ៩ |
| ច. អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល | | |
| ១ | GGGI | ១ |
| ២ | Habitat for Humanity | ១ |
| ៣ | People In Need | ១ |
| ៤ | Community Development Foundation | ១ |
| ៥ | Cambodia Institute for Urban Studies (CIUS) | ១ |
| ៦ | Asia Foundation | ១ |
| ៧ | Urban Poor Women Development | ១ |
| ៨ | WaterAid Cambodia | ១ |
| ៩ | GRET | ១ |
| ១០ | AIMF | ១ |
| | សរុបរង | ១០ |
| ឆ. ស្ថាប័នសិក្សាស្រាវជ្រាវ | | |
| ១ | សកលវិទ្យាល័យភូមិន្ទកសិកម្ម | ២ |
| ២ | សកលវិទ្យាល័យផារ៉ាហ្គន | ៤ |
| ៣ | សកលវិទ្យាល័យវេស្ទើន | ១ |
| ៤ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧ |
| ៥ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ១៤ |
| ៦ | សកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៣ |
| ៧ | សកលវិទ្យាល័យបញ្ញាសាស្ត្រ | ៣ |
| ៨ | សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | ២ |
| ៩ | សកលវិទ្យាល័យន័រតុន | ១ |
| ១០ | វេទិកាអនាគត | ៤ |
| | សរុបរង | ៤១ |
| ជ. វិស័យឯកជន | | |
| ១ | Acleda Bank | ១ |
| ២ | Royal Group | ៣ |
| ៣ | Borey Peng Huot | ១ |
| ៤ | WorldBridge Group | ១ |

| | | |
|---|---|---|
| ៥ | Cambodia Chamber of Commerce | ២ |
| ៦ | Phnom Penh Special Economic Zone | ១ |
| ៧ | Mitsubishi Cambodia | ១ |
| ៨ | Urban Living Solutions | ២ |
| ៩ | GoGreen Cambodia | ១ |
| ១០ | Archetype | ១ |
| ១១ | Young Entrepreneurs Association of Cambodia | ១ |
| ១២ | Eurocham | ១ |
| ១៣ | Ecosun | ១ |
| ១៤ | Arup | ១ |
| ១៥ | Cambodia Constructors Association | ១ |
| ១៦ | Board of Architectures of Cambodia | ១ |
| ១៧ | Ramboll | ១ |
| ១៨ | PS Union Construction | ១ |
| ១៩ | PCLA | ១ |
| ២០ | CKS | ១ |
| ២១ | Lukcy Reality | ១ |
| ២២ | RBG | ១ |
| ២៣ | Eastern Construction & Investment | ១ |
| ២៤ | The Room Design Studio | ១ |
| ២៥ | Dynamic Technologies | ១ |
| ២៦ | Bun&Associate | ១ |
| ២៧ | RWST | ១ |
| ២៨ | Amatak Property Service | ២ |
| ២៩ | CRC Cambodia | ១ |
| ៣០ | Phnom Penh Water Supply Authority | ១ |
| | សរុបរង | ៣៥ |
| ឈ. អ្នកសារព័ត៌មាន | | |
| ១ | Khmer Times | ៣ |
| ២ | Property Area Asia | ១ |

| | | |
|---|---|---|
| ៣ | KHB | ១ |
| ៤ | RNK | ២ |
| ៥ | Phnom Penh Post | ២ |
| ៦ | CNC | ២ |
| ៧ | VCMOFM | ១ |
| ៨ | Freshnews | ១ |
| ៩ | APSARA | ១ |
| | សរុបរង | ១៤ |
| | សរុប | ២៣៦ |

# ឧបសម្ព័ន្ធទី ៣៖ របាយការណ៍នៃកិច្ចប្រជុំមុនវេទិកា

**របាយការណ៍នៃកិច្ចប្រជុំមុនវេទិកាជាមួយភាគីពាក់ព័ន្ធ**
**ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩**

**១. សេចក្តីផ្តើម**

កិច្ចប្រជុំនៅមុនវេទិកាត្រូវបានរៀបចំធ្វើឡើងកាលពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ តបតាមការអញ្ជើញរបស់ប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជាដើម្បីប្រមូលធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយពីស្ថាប័ន អង្គការពាក់ព័ន្ធសម្រាប់លើកឡើងនៅក្នុងវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១។ កិច្ចប្រជុំនេះសម្របសម្រួលក្នុងទម្រង់ជាការពិភាក្សាតុមូល និងផ្តល់ឱកាសឱ្យមានការពិភាក្សា ការពិនិត្យ និងការផ្តល់ធាតុចូលលើបញ្ហាប្រឈម និងអាទិភាពសំខាន់ៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាពនៅកម្ពុជា។ ការពិភាក្សាតុមូលនេះក៏ជាឱកាសដើម្បីឱ្យភាគីពាក់ព័ន្ធនានាត្រៀមរៀបចំផ្តល់ជាគំនិតយោបល់ និងលើកសំណើបញ្ចូលទៅក្នុងឯកសារលទ្ធផល និងជំហានបន្ទាប់សម្រាប់បន្តតាមដានក្រោយវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១។ ទីភ្នាក់ងារសហប្រជាជាតិបានរៀបចំកិច្ចប្រជុំនេះនៅការិយាល័យរបស់ UNOPS ។ តំណាងភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំនេះរួមមានតំណាងមកពីស្ថាប័នសិក្សាស្រាវជ្រាវ ស្ថាប័នធុរកិច្ច អ្នករៀបចំផែនការ និងអ្នកជំនាញនគរូបនីយកម្ម ដៃគូអភិវឌ្ឍន៍ ក្រុមសង្គមស៊ីវិល និងក្រុមងាយរងគ្រោះដូចជាស្ត្រី យុវជន និងជនមានពិការភាពជាដើមដែលមានចំនួន ៣៤ នាក់ មកពីអង្គការចំនួន ២០ដូចមានក្នុងឧបសម្ព័ន្ធ។

អ្នកចូលរួមបានបែងចែកជា ៣ ក្រុមដើម្បីធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ដើម្បីឆ្លើយសំណួរនាំមុខដូចតទៅ។ សំណួរ៣ដំបូងពាក់ព័ន្ធនឹងប្រធានបទសំខាន់ៗចំនួន ៣ នៅក្នុងវេទិកា៖ ១)ទិដ្ឋភាពរួមទូទៅអំពីការអភិវឌ្ឍទីក្រុង/នគរូបនីយកម្ម៖ ស្ថានភាព បញ្ហាប្រឈម និងកាលានុវត្តភាព, ២)ការដាក់អាទិភាពទីក្រុងរបស់កម្ពុជា៖ ការជំរុញការអនុវត្តគោលនយោបាយ និងការសម្រេច ឱ្យបាននូវទីក្រុងប្រកបដោយចីរភាព, ៣)ការផ្តល់ហិរញ្ញប្បទានទីក្រុង, ៤)ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍទីក្រុង និង ៥)តួនាទីរបស់ដៃគូអភិវឌ្ឍន៍។ សេចក្តីលម្អិតអំពីការពិភាក្សាមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី ៣។

**២. សេចក្តីព្រាងរបៀបវារៈ**

| | |
|---|---|
| ០៨:០០-០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម |
| ០៨:៣០-០៨:៤០ | ការណែនាំ និងវត្ថុបំណងនៃកិច្ចប្រជុំ (Laxman Perera, UN-Habitat) |
| ០៨:៤០-០៩:០០ | ការបង្ហាញដោយសង្ខេប សំណួរនិងចម្លើយ (Lars Stordal, UN-Habitat) |
| ០៩:០០-០៩:២០ | សម្រាក និងបែងចែកជា ៣ ក្រុមពិភាក្សា |
| ០៩:២០-១១:០០ | កិច្ចពិភាក្សាតាមក្រុមអំពីសេចក្តីព្រាងសេចក្តីថ្លែងការស្តីពីចក្ខុវិស័យ(Miguel Garcia, UNOPS) ពាក់ព័ន្ធនឹង **១)ទិដ្ឋភាពរួមទូទៅអំពីការអភិវឌ្ឍទីក្រុង/នគរូបនីយកម្ម៖ ស្ថានភាព បញ្ហាប្រឈម និងកាលានុវត្តភាព, ២)ការដាក់អាទិភាពទីក្រុងរបស់កម្ពុជា៖ ការលើកកម្ពស់គោលនយោបាយ និងការសម្រេចឱ្យបាននូវទីក្រុងប្រកបដោយចីរភាព, ៣) ការផ្តល់ហិរញ្ញប្បទានទីក្រុង** |

| | |
|---|---|
| ១១:០០-១១:៤០ | ការធ្វើបទបង្ហាញរបស់ក្រុម/ មតិត្រឡប់ សំណួរនិងចម្លើយ (Kristin Parco, IOM) |
| ១១:៤០-១២:០០ | សុន្ទរកថាបិទកិច្ចប្រជុំ (Kristin Parco, IOM) |

**៣. ការពិភាក្សាតាមក្រុម**

អ្នកចូលរួមបានបែងចែកជា ៣ ក្រុមដើម្បីផ្លាស់ប្តូរយោបល់ និងពិភាក្សាអំពីសំណួរនាំមុខ ៣ ដំបូងពាក់ព័ន្ធនឹងកិច្ចប្រជុំបែងចែកតាមប្រធានបទសំខាន់ៗចំនួន ៣ នៃវេទិកានគរូបនីយកម្មកម្ពុជាលើកទី ១÷

**៣.១. វេទិការួមទូទៅអំពីការអភិវឌ្ឍទីក្រុង/ នគរូបនីយកម្ម÷ ស្ថានភាព បញ្ហាប្រឈម និងកាលានុវត្តភាព**

*តើមានបញ្ហាប្រឈមធំៗចំនួន ៣ អ្វីខ្លះដែលអ្នកគិតថា មានភាពពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍទីក្រុងឬនគរូបនីយកម្មនៅកម្ពុជា? តើមានមូលហេតុជាឫសគល់អ្វីខ្លះដែលនាំឱ្យមានបញ្ហាទាំងនេះ និងថាតើគេអាចដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា? តើអ្នកធ្វើយ៉ាងដូចម្តេចដើម្បីឱ្យប្រជាពលរដ្ឋចូលរួមដោះស្រាយបញ្ហាទាំងនេះ?*

**សង្ខេប÷**

**បញ្ហាប្រឈមសំខាន់ជាងគេបំផុតនៅក្នុងទីក្រុងនៅកម្ពុជាបែងចែកជា ៣ ប្រភេទធំៗ÷**

**១. គុណភាពបរិស្ថាន**

ក. ការបំពុលខ្យល់ និងទឹកក្នុងកម្រិតខ្ពស់

ខ. ការគ្រប់គ្រងសំណល់រាវ និងសំណល់រឹងពុំបានល្អ

គ. ទីធ្លាបៃតងសាធារណៈសម្រាប់ប្រជាជនជួបជុំគ្នា និងការកម្សាន្តនៅមានគុណភាពទាប។

**២. ចល័តភាព**

ក. ការកកស្ទះចរាចរណ៍

ខ. ការខ្វះកន្លែងចតយានយន្ត

គ. បណ្តាញគមនាគមន៍សាធារណៈនៅមានកម្រិតខ្សោយ

ឃ. ការប្រើលើសកម្រិតនូវមធ្យោបាយធ្វើដំណើរជាលក្ខណៈឯកជនដែលប្រើប្រេងឥន្ធនៈ

ង. មនុស្សមិនផ្លាស់ទីដោយថ្មើរជើងឡើយ ព្រោះថាពុំមានផ្លូវសម្រាប់ថ្មើរជើង

ច. ការគោរពច្បាប់ចរាចរណ៍នៅមានកម្រិតទាប។

**៣. ការទទួលបានធនធាន និងសេវាប្រកបដោយសមធម៌**

ក. ពុំមានទឹកស្អាត និងខ្យល់ស្អាតសម្រាប់ទាំងអស់គ្នា

ខ. ការផ្គត់ផ្គង់អគ្គិសនីមិនមានសម្រាប់ទាំងអស់គ្នា

គ. ការប្រើធនធានលើសកម្រិតដោយប្រជាជនមួយក្រុមតូច (អ្នកដែលមានជីវភាពធូរធារ) បង្កផលប៉ះពាល់ដល់ ភាព

អាចរកបាននៃធនធានដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់មនុស្សភាគច្រើន (ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ ឬអ្នកដែលរស់នៅតំបន់ជនបទ)

ឃ. ការបែងចែកដីមិនស្មើភាពគ្នា (ប្រជាពលរដ្ឋក្រីក្រត្រូវបានបណ្តេញចេញពីដីធ្លីរបស់ពួកគេទៅតំបន់ជាយក្រុងដែលធ្វើឱ្យជីវិតរបស់ពួកគេមានភាពរីកចម្រើនតិចតួច ឬពុំមានការរីកចម្រើន)

ង. ខ្វះលិខិតបទដ្ឋានគតិយុត្តស្តីពីការបែងចែកដីសាធារណៈ

ច. ពុំមានទីធ្លាសាធារណៈឱ្យបានគ្រប់គ្រាន់សម្រាប់ឱ្យប្រជាជនប្រមូលផ្តុំ និងកម្សាន្តសប្បាយ

ឆ. ពុំមានផ្លូវដើរ ឬគន្លងសម្រាប់ថ្មើរជើង

ជ. តំបន់លំនៅឋានមិនរៀបរយ

ឈ. មានការកើនឡើងដោយពុំមានការគ្រប់គ្រង។

**ដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ÷**

**គុណភាពបរិស្ថាន÷**

- មានការដាក់ចេញនូវគោលនយោបាយមួយចំនួនរួច ប៉ុន្តែការអនុវត្តនៅមានកម្រិត
- ភាគីពាក់ព័ន្ធនៅមូលដ្ឋានគួររួមគ្នាដើម្បីបង្កើនការយល់ដឹង និងអប់រំប្រជាពលរដ្ឋអំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងបរិស្ថាននៅក្នុងទីក្រុង
- កែលម្អ និងបង្កើនតម្លាភាពនៃសេវាគ្រប់គ្រងសំណល់ និងសម្របសម្រួលលំហូរចរាចរណ៍ឱ្យកាន់តែប្រសើរ
- រៀបចំផែនការប្រើប្រាស់ដី និងសកម្មភាពនានាឱ្យកាន់តែប្រសើរ
- ការរចនាសម្រាប់តំបន់អភិវឌ្ឍន៍ទីក្រុងថ្មី (ស្ថាបត្យកម្ម ឬវិស្វកម្ម) គួរបញ្ចូលយុទ្ធសាស្ត្រដែលមានលក្ខណៈច្នៃប្រឌិតថ្មីដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ
- ពង្រឹងការអនុវត្តការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាលក្ខណៈឯករាជ្យសម្រាប់ការអភិវឌ្ឍគ្រប់ប្រភេទ។

**ចល័តភាព÷**

- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍
- យកពន្ធច្រើនជាងមុនលើមធ្យោបាយធ្វើដំណើរដែលប្រើប្រាស់លក្ខណៈបុគ្គល និងប្រើប្រេងឥន្ធនៈ ដើម្បីកាត់បន្ថយចំនួនរថយន្ត (ធំៗ) និងទោចក្រយានយន្តនៅតាមដងផ្លូវ និងផ្លូវថ្មើរជើង
- បង្កើនការយល់ដឹង ឬផ្លាស់ប្តូរឥរិយាបថដើម្បីកាត់បន្ថយការប្រើប្រាស់រថយន្ត និងទោចក្រយានយន្ត (ដើរ ឬជិះកង់សម្រាប់ផ្លូវដែលមានចម្ងាយខ្លី)
- រៀបចំផែនការទីក្រុងឱ្យបានប្រសើរជាងមុនដើម្បីអាចរកបានសេវាសាធារណៈគ្រប់បែបយ៉ាងក្នុងចម្ងាយដ៏ខ្លី
- អប់រំ និងជំរុញឱ្យមានការប្រើប្រាស់កង់ ឬការដើរថ្មើរជើងជាមធ្យោបាយសម្រាប់ការធ្វើដំណើរ
- បង្កើនសុវត្ថិភាពនៅតាមផ្លូវដើម្បីឱ្យប្រជាជនមិនចាំបាច់ធ្វើដំណើរទៅណាមកណាដោយរថយន្ត និងធ្វើឱ្យទីក្រុងក្លាយជាកន្លែងសម្រាប់ប្រជាជនអាចដើរជុំគ្នា អ្នកជិតខាងទំនាក់ទំនងគ្នានៅទីធ្លាសាធារណៈនិងទំនាក់ទំនងល្អទៅវិញទៅមក ជឿទុកចិត្តគ្នាទៅវិញទៅមក។ល។ ទាំងនេះគឺជាអ្វីដែលបង្កើតបាននូវសុវត្ថិភាព។

**ការទទួលបានធនធាន និងសេវាកម្ម÷**

- សម្រួលនីតិវិធីទទួលបានសិទ្ធិកាន់កាប់ដីធ្លីដើម្បីឱ្យម្ចាស់ដី (ប្រជាពលរដ្ឋក្រីក្រពិតប្រាកដ) នឹងមិនត្រូវបានបណ្តេញចេញពីដីរបស់ខ្លួន ហើយជីវភាពរបស់ពួកគាត់អាចមានភាពល្អប្រសើរជាងមុននៅនឹងទីតាំងផ្ទាល់ជាជាងត្រូវចាកចេញទៅរស់នៅតំបន់ដាច់ស្រយាល
- ជំរុញឱ្យមានការប្រើប្រាស់អគ្គិសនីពីប្រភពផ្សេងទៀតដែលមានចីរភាព
- អប់រំផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋដើម្បីឱ្យអាចប្រើប្រាស់ធនធាន (ទឹក និងអគ្គិសនី) កាន់តែសមស្រប និងប្រកបដោយការទទួលខុសត្រូវសំដៅធ្វើយ៉ាងណាឱ្យមានធនធានគ្រប់គ្រាន់សម្រាប់ទាំងអស់គ្នា
- ជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធសាងសង់បែបថ្មីដែលកាន់តែសន្សំសំចៃធនធាន
- រាជរដ្ឋាភិបាលត្រូវកំណត់តម្លៃអគ្គិសនីទៅតាមប្រភេទនៃការប្រើប្រាស់តាមពេលវេលានៅក្នុងថ្ងៃ(កាត់បន្ថយតម្លៃនៅពេលប្រើប្រាស់អគ្គិសនីខុសពីម៉ោងដែលមានមនុស្សប្រើប្រាស់ច្រើន)
- រាជរដ្ឋាភិបាលចាំបាច់ត្រូវថ្លឹងថ្លែងរវាងការអភិវឌ្ឍ និងការអភិរក្សដោយធ្វើការពិចារណាឱ្យបានប្រុងប្រយ័ត្នពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសនីមួយៗ និងខិតខំផ្តល់អត្ថប្រយោជន៍ដល់ប្រជាជន
- ជំរុញឱ្យមានការរៀបចំវេទិកាសម្រាប់ប្រជាពលរដ្ឋមកពីគ្រប់ស្រទាប់វណ្ណៈ (អ្នកដែលមានជីវភាពធូរធារ ក្រីក្រ រដ្ឋ ឯកជន អង្គការក្រៅរដ្ឋាភិបាល។ល។) ដើម្បីអាចឱ្យទាក់ទងគ្នា សហការគ្នា និងចូលរួមក្នុងការតាក់តែងគោលនយោបាយនៅកម្រិតមូលដ្ឋាន។
- រាជរដ្ឋាភិបាលត្រូវផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានាដែលមានលើការកសាងសហគមន៍ កែលម្អការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ (សេរីភាពនៃការបញ្ចេញមតិយោបល់ ព័ត៌មានអាចមានសម្រាប់គ្រប់វិស័យនៅក្នុងសង្គម។ល។) បង្កើនការអប់រំ និងការយល់ដឹងអំពីផ្នែកពាក់ព័ន្ធដូចលើកឡើងខាងលើ។

**យោបល់ចុងក្រោយ÷**

- បញ្ហាប្រឈម និងដំណោះស្រាយទាំងនេះសុទ្ធតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក ដូច្នេះតាមរយៈការដោះស្រាយបញ្ហាប្រឈមដែលមានលក្ខណៈជាយុទ្ធសាស្ត្រនោះបញ្ហាប្រឈមដទៃទៀតក៏នឹងបានធូរស្រាលទៅតាមនោះដែរ។
- ផ្នែកសំខាន់បំផុតគឺត្រូវចងចាំថា **ត្រូវតែមានការរៀបចំទីក្រុងសម្រាប់ប្រជាជន និងដោយប្រជាជនដែលរស់នៅក្នុងទីក្រុងនោះ។** ដូច្នេះការវិនិយោគលើការអប់រំ និងការទំនាក់ទំនងកាន់តែប្រសើរដើម្បីផ្តល់ភាពអង់អាចដល់ប្រជាជនចូលរួមក្នុងការតាក់តែងគោលនយោបាយ និងការផ្លាស់ប្តូរឥរិយាបថ គឺជាជំហានដំបូងដ៏សំខាន់សម្រាប់គ្រប់ផ្នែកដែលត្រូវបានលើកឡើងខាងលើ។
- លើសពីនេះមានការលើកឡើងពីភាពចាំបាច់ក្នុង**ការពង្រឹងការអនុវត្តច្បាប់និងគោលនយោបាយដែលមានស្រាប់**នៅពេលដែលធ្វើការពិចារណារិះរកវិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនេះ។

## ៣.២. ការដាក់អាទិភាពទីក្រុងរបស់កម្ពុជា÷ ការលើកកម្ពស់គោលនយោបាយ និងការសម្រេចឱ្យបាននូវទីក្រុងប្រកបដោយចីរភាព

*តើអ្នកគិតថា ទីក្រុងនាពេលអនាគតនៅកម្ពុជាគួរមានលក្ខណៈបែបណា? តើគួរមានគោលនយោបាយជាអាទិភាពសំខាន់ៗអ្វីខ្លះដើម្បីឈានទៅធានាឱ្យដំណើរការអភិវឌ្ឍទីក្រុងឬនគរូបនីយកម្មនៅប្រទេសកម្ពុជា មានចីរភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរយៈពេលវែងរបស់ប្រជាជនទាំងអស់? ឬនិយាយម្យ៉ាងទៀត តើចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរអ្វីខ្លះនៅថ្ងៃនេះដើម្បីសម្រេចនូវចក្ខុវិស័យនេះក្នុងពេលឆាប់ៗ? តើចាំបាច់ត្រូវធ្វើសកម្មភាពអ្វីខ្លះនិងនរណាខ្លះដែលត្រូវធ្វើសកម្មភាពទាំងនេះ?*

សង្ខេប÷

- ធានាឱ្យមានការរៀបចំផែនការ និងការគ្រប់គ្រងឱ្យបានល្អនៅក្នុងទីក្រុង ក្នុងនោះការគិតពិចារណាលើគ្រប់វិស័យដូចជាទឹកស្អាត ដឹកជញ្ជូន សំណល់រឹងនិងរាវ។ល។ ត្រូវបានធ្វើឡើងមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងប្រទាក់ក្រឡាគ្នា
- ទីក្រុងគួរមានអនាម័យស្អាត ពុំមានសំរាមនៅតាមផ្លូវ មានការគ្រប់គ្រងធនធានឱ្យកាន់តែប្រសើរ
- ការធ្វើដំណើរនៅក្នុងទីក្រុងមិនគួរលើសពីរយៈពេលដែលបានកំណត់ (មានការលើកឡើងឱ្យក្រោម ៣០ នាទី) ហើយការធ្វើដំណើរក្នុងភាគរយខ្ពស់(៨០%) គួរធ្វើឡើងតាមរយៈមធ្យោបាយធ្វើដំណើរសាធារណៈ និងតាមថ្មើរជើង។ បញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះគឺពុំមានសុវត្ថិភាព និងពុំមានគន្លងផ្លូវសម្រាប់ដើរ
- គួររៀបចំផែនការទីក្រុងដោយគិតចេញពីជ្រុងប្រជាជននិងសហគមន៍។ គួរប្រើប្រាស់អភិក្រមរៀបចំទីក្រុងដែលមានលក្ខណៈក្តោបរួម ពោលគឺក្តោបលើស្មារតីសហគមន៍ដែលប្រទេសកម្ពុជានៅមាន (ចំណុចខ្លាំងដ៏ធំ)។ ទីក្រុងគួរមានសុវត្ថិភាពនិងផ្តល់ភាពងាយស្រួលដល់ប្រជាជនគ្រប់រូបរាប់បញ្ចូលទាំងកុមារដែលអាចដើរទៅកាន់សាលារៀន។មិនគួរមានការបែងចែកសហគមន៍ទៅតាមកម្រិតចំណូលខុសៗគ្នា នោះឡើយ ពោលគឺ “**គ្មានអ្នកដទៃ**” ឡើយ
- ទីក្រុងគួរកសាងអត្តសញ្ញាណសម្រាប់ខ្លួនឯង គួរមានការអភិរក្សអគារចាស់ៗនិងបេតិកភណ្ឌក្នុងទម្រង់ផ្សេងទៀត
- ទីក្រុងគួរមានឧទ្យានឱ្យបានគ្រប់គ្រាន់ និងលំហសាធារណៈផ្សេងទៀតដែលប្រើប្រាស់សម្រាប់ការជួបជុំការប្រមូលផ្តុំជាសាធារណៈ ជួយសម្រួលដល់ការផ្លាស់ទីរបស់ប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត និងបំពេញតម្រូវការផ្សេងទៀត។ លំហសាធារណៈមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់សុភមង្គលសង្គម។
- រាជរដ្ឋាភិបាលគួរសម្របសម្រួលឱ្យមានរបាយប្រជាជនសមស្របនៅតាមទីក្រុងទីប្រជុំជននិងភូមិចាប់ពីតំបន់ទីប្រជុំជនរហូតដល់តំបន់ជនបទដើម្បីបញ្ចៀសការកកស្ទះ និងសម្ពាធមកលើសេវាមូលដ្ឋាន។
- ទីក្រុងនានាកំពុងស្ថិតនៅផ្លូវខ្វែងក្នុងគន្លងនៃការអភិវឌ្ឍ ឧទាហរណ៍ខេត្តបាត់ដំបងមានឱកាសដ៏ធំធេងក្នុងការដាក់ឱ្យអនុវត្តផែនការគ្រប់គ្រងទីក្រុងឱ្យល្អប្រសើរ
- លំនៅឋានគួរមានតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋដែលមានចំណូលទាប និងប្រជាពលរដ្ឋក្រីក្រ។ ទាំងនេះគឺជាតួនាទីរបស់រាជរដ្ឋាភិបាលត្រូវបន្តបំពេញដើម្បីឱ្យគោលដៅនេះក្លាយជាតថភាពតាមរយៈការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ការផ្តល់ឧបត្ថម្ភធន និងឧបករណ៍ផ្សេងទៀត

- ការខ្វែងមតិរវាងមតិកម្រិតនយោបាយនិងមតិកម្រិតបច្ចេកទេសដែលទាមទារឱ្យមានការសម្របសម្រួលអន្តរក្រសួងស្ថាប័ន
- គួរពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវានៅនឹងមូលដ្ឋាន។ការពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋានគួរធ្វើឡើងផ្អែកតាមក្របខណ្ឌបទដ្ឋានគតិយុត្តដែលមានភាពច្បាស់លាស់និងឆ្លុះបញ្ចាំងពីអាទិភាពនិងការបែងចែកធនធាន
- គួរមានការបង្កើនតម្លាភាពក្នុងការចំណាយធនធាន និងការគ្រប់គ្រងធនធាន
- សហគមន៍មូលដ្ឋានគួរចូលរួមជាមួយនឹងរាជរដ្ឋាភិបាលនៅកម្រិតផ្សេងៗដូចជាអាជ្ញាធរមូលដ្ឋាន ឬរដ្ឋបាលថ្នាក់ក្រុងជាដើម។ អាជ្ញាធរមូលដ្ឋានគួរទទួលបានអំណាចដើម្បីអាចចូលរួមសម្រុះសម្រួលជាមួយនឹងសហគមន៍ដើម្បីស្តាប់ពីតម្រូវការរបស់ខ្លួន និងឆ្លើយតបចំពោះតម្រូវការទាំងនេះ។ គួរមានការផ្តល់ការគាំទ្រដល់កម្មវិធីនានាដែលអនុវត្តដើម្បីឈានទៅសម្រេចគោលបំណងនេះដូចជាកម្មវិធី ISAF ២ (ផែនការអនុវត្តន៍គណនេយ្យភាពសង្គមជាដើម)។

## ៣.៣. ការផ្តល់ហិរញ្ញប្បទានដល់ទីក្រុង

*តើចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីធានាឱ្យមានការផ្តល់ហិរញ្ញប្បទានគាំទ្រដល់ការអនុវត្តសកម្មភាពនានា? តើឧបករណ៍ហិរញ្ញប្បទានអាចជួយឱ្យទីក្រុងទទួលបានសម្ភារបរិក្ខារកាន់តែល្អប្រសើរជាងមុនដោយរបៀបណា? តើគេអាចកៀរគរធនធាននៅនឹងមូលដ្ឋាន (ធនធានពីប្រភពផ្ទាល់ខ្លួន) បានដោយរបៀបណា?*

**សង្ខេប÷**

- ការតាក់តែងគោលនយោបាយដើម្បីបង្កើនសមត្ថភាពវិនិយោគរបស់ទីក្រុង។ ផ្តល់ភាពអង់អាចដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានក្នុងក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលមានភាពច្បាស់លាស់ដើម្បីទាក់ទងនិងគ្រប់គ្រងការវិនិយោគ
- សហគ្រាសខ្នាតតូចនិងមធ្យម និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀតអាចបំពេញកង្វះធនធានថវិកាតិចតួច
- ពង្រឹងការប្រមូលពន្ធនៅតាមមូលដ្ឋាន កសាងគណនេយ្យភាព និងទាក់ទាញចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋឱ្យចូលរួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងលើកកម្ពស់គណនេយ្យភាពនៅនឹងមូលដ្ឋាន។

## ៣.៤. ការជំរុញឱ្យភាគីពាក់ព័ន្ធចូលរួមក្នុងការអភិវឌ្ឍទីក្រុង

*តើស្ថាប័នពាក់ព័ន្ធ (ដូចជាអង្គការក្រៅរដ្ឋាភិបាល) អាចរួមចំណែកអ្វីខ្លះក្នុងដំណើរការនេះ? តើស្ថាប័នទាំងនេះគួរមានតួនាទីអ្វីខ្លះនៅក្នុងអភិបាលកិច្ចទីក្រុង?*

**សង្ខេប÷**

- ការរៀបចំ ការអនុវត្ត និងការពិនិត្យលើគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលគួរមានការចូលរួម

ពីភាគីពាក់ព័ន្ធនានា

- ស្ថាប័នពាក់ព័ន្ធជាច្រើនដូចជាវិស័យឯកជន វិស័យមិនរកប្រាក់ចំណេញ អង្គការតាមសហគមន៍ និងសង្គមស៊ីវិលជាដើមអាចរួមចំណែកផ្តល់ជាទិន្នន័យ និងរបាយការណ៍ដែលជួយផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ទីក្រុង។ ឧទាហរណ៍ការដឹងពីទីតាំងរបស់សាលារៀនឯកជន និងទីតាំងរបស់សិស្សដែលរៀននៅតាមសាលារៀនទាំងនោះអាចជួយបង្កើតរូបភាពជារួមអំពីការធ្វើដំណើរនៅក្នុងទីក្រុងរបស់សិស្ស។ ទាំងនេះគឺជាព័ត៌មានដែលអាចរាយការណ៍ក្នុងប្រព័ន្ធនៅថ្នាក់ជាតិសម្រាប់ផ្តល់ជាព័ត៌មានដល់ការរៀបចំគោលនយោបាយ និងដំណើរការនានា
- ស្ថាប័នពាក់ព័ន្ធគួរជំរុញឱ្យមានការអនុលោមតាមគោលការណ៍ស្តីពីការធានាសុវត្ថិភាពបរិស្ថាន និងសង្គម។ ឧទាហរណ៍គួរទាក់ទាញក្រុមហ៊ុនអចលនទ្រព្យ(ជាពិសេសក្រុមហ៊ុនអន្តរជាតិធំៗ) ឱ្យចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់អាជ្ញាធរមូលដ្ឋានដើម្បីឱ្យវិស័យអចលនទ្រព្យអាចរួមកម្លាំងឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍
- ស្ថាប័នពាក់ព័ន្ធគួរបំពេញតួនាទីសំខាន់ក្នុងដំណាក់កាលរៀបចំគម្រោងនានាដើម្បីឱ្យគម្រោងទាំងនោះមានភាពសមស្របទៅតាមគោលបំណងរបស់ខ្លួន
- កំណត់ពីកង្វះទុនវិនិយោគខ្នាតធំ និងផ្តល់ឱកាសឱ្យអង្គការក្រៅរដ្ឋាភិបាលបំពេញកង្វះទាំងនោះ។

### ៣.៥. តួនាទីរបស់ដៃគូអភិវឌ្ឍន៍

*តើដៃគូអភិវឌ្ឍន៍ដូចជាអ្នកផ្តល់ជំនួយទ្វេភាគី ធនាគារអភិវឌ្ឍន៍ និងប្រព័ន្ធអង្គការសហប្រជាជាតិគួរបំពេញតួនាទីអ្វីខ្លះ ?*

**សង្ខេប៖**

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលដើម្បីធានាការអនុវត្តគោលនយោបាយ និងផែនការនានាឱ្យកាន់តែប្រសើរ
- ផ្តល់ថវិកាដល់សិស្សនិស្សិតដែលចង់សិក្សាជំនាញរៀបចំទីក្រុងនៅតាមបណ្តាប្រទេសនានាក្នុងពិភពលោក
- ជំរុញកិច្ចសហការរវាងគ្នាទៅវិញទៅមក និងបង្កើនការយល់ដឹងអំពីហានិភ័យនានាដែលពាក់ព័ន្ធនឹងគម្រោងផ្តល់ការគាំទ្រនីមួយៗ
- ភ្ជាប់ទំនាក់ទំនង (Connecting the dots) > ភាពជាដៃគូ > Broker។

## ៤. សេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយលោកស្រី គូ ស៊ីណា ប្រធានកម្មវិធីអភិវឌ្ឍន៍ទីក្រុង

### សម្រាប់ស្ត្រីក្រីក្រការសម្តែងមតិពីអង្គការសង្គមស៊ីវិល

អង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលបានអនុវត្តគម្រោងគាំទ្រដល់សហគមន៍ក្រីក្រតាមរាជធានី ទីក្រុង និងទីប្រជុំជនយល់ឃើញថា នៅប៉ុន្មានឆ្នាំចុងក្រោយនេះនគរូបនីយកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ ហើយ

បាននិងកំពុងតែពង្រីកផ្ទៃក្រឡាយ៉ាងឆាប់រហ័សដែលជាកាលានុវត្តភាពក្នុងការរីកចម្រើនសេដ្ឋកិច្ចនិងគ្រប់វិស័យ ជាពិសេសរាជរដ្ឋាភិបាលក៏បានរៀបចំគោលនយោបាយជាច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការអនុវត្តប្រកបដោយចីរភាពសម្រាប់ប្រជាជនទូទៅ និងសហគមន៍ក្រីក្រ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង ២៥រាជធានី ខេត្តដើម្បីឱ្យចូលរួមគាំទ្រ និងអនុវត្តគោលនយោបាយ និងសារាចរណែនាំជាធរមានក្នុងគោលបំណងធ្វើឱ្យប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប មធ្យម និងក្រុមជនងាយរងគ្រោះមានលទ្ធភាពអាចរស់នៅក្នុងលំនៅឋានសមរម្យនិងថ្លៃថ្នូរដូចពលរដ្ឋដទៃទៀតដែរ ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ និង កតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌។

យើងក៏បានសង្កេតឃើញថាតួនាទីរបស់ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសុឆន្ទៈខ្ពស់កំណត់ផែនការសកម្មភាពការងាររបស់ខ្លួនដើម្បីឆ្ពោះទៅរកដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហានានាដូចជាករណីសំណង់បណ្តោះអាសន្ន ឬសំណង់មិនរៀបរយ  នគរូបនីយកម្ម សុខភាពសាធារណៈ ការអប់រំសាធារណជន  សេវាសាធារណៈនៅមូលដ្ឋានផ្សេងៗឱ្យមានលទ្ធភាព និងផ្តល់នូវភាពងាយស្រួលក្នុងការទទួលបាននូវលំនៅឋានសមរម្យ។ ជាក់ស្តែងសំណង់បណ្តោះអាសន្នមួយចំនួនត្រូវបានដោះស្រាយជូនប្រជាពលរដ្ឋដែលរស់នៅសហគមន៍តាមដងប្រឡាយទឹកកខ្វក់ស្ទឹងមានជ័យ សហគមន៍ទំនប់ ២ សហគមន៍សំរោងមានជ័យសែនសុខ សហគមន៍វាលស្បូវ និង អគារបូឌិញជាដើម។ សកម្មភាពនេះទទួលបានការអបអរសាទរពីប្រជាពលរដ្ឋទូទៅ មតិជាតិ មតិអន្តរជាតិ និងមតិអង្គការមិនមែនរដ្ឋាភិបាលពីព្រោះបានផ្តល់សំណងសមរម្យ និងយុត្តិធម៌ស្របតាមតម្លៃទីផ្សារជាក់ស្តែង បានពិគ្រោះយោបល់ពេញលេញ និងបានដោះស្រាយតាមជម្រើសរបស់ប្រជាពលរដ្ឋ ពិសេសសហគមន៍ក្លាយជាម្ចាស់កម្មសិទ្ធិ រក្សាបាននូវមុខរបរ សេវាមូលដ្ឋាន និងការអប់រំ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានសហការជាមួយក្រុមហ៊ុនឯកជនរៀបចំឱ្យមានគម្រោងអភិវឌ្ឍន៍លំនៅឋានសមរម្យសម្រាប់លក់ជូនប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងមធ្យម។

យើងក៏ឃើញមានគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រហៅកាត់ថា “**គម្រោងលាភ**” ដែលសហការរវាងដៃគូអភិវឌ្ឍន៍ធនាគារពិភពលោក ក្រសួងមហាផ្ទៃ សាលារាជធានីភ្នំពេញ និងសាលាខេត្តសៀមរាបបានជួយដល់សហគមន៍រស់នៅសំណង់បណ្តោះអាសន្ន ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមុខរបរ ក្រុមសន្សំប្រាក់ កសាងហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រក្នុងសហគមន៍។ ពិសេសជាងនេះទៅទៀត ចុងក្រោយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ឱ្យអាជ្ញាធរដែនដី និងមន្ត្រីជំនាញចុះពិនិត្យឡើងវិញលើស្ថាបត្យកម្ម និងច្បាប់ស្តីពីសំណង់ដើម្បីធានាគុណភាព សុវត្ថិភាព និងសោភ័ណភាពដល់ការរស់នៅរបស់ប្រជាជន។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះ និងទោះបីមានឆន្ទៈក្នុងការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលបានកត់សម្គាល់ឃើញថា នៅកម្ពុជាមិនទាន់មានគោលនយោបាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងនគរូបនីយកម្ម និងការអភិវឌ្ឍរាជធានីនិងទីក្រុងប្រកបដោយចីរភាព ការអភិវឌ្ឍដើម្បីទាំងអស់គ្នាដោយភាពឆ្លាតវៃ ការអភិវឌ្ឍឱ្យមានស្តង់ដារួមនៅឡើយ ពោលគឺគោលនយោបាយទាំងនេះត្រូវបានប្រើប្រាស់ទៅតាមករណីនីមួយៗនៃគម្រោងអភិវឌ្ឍតែប៉ុណ្ណោះ ពិសេសមិនទាន់មានគោលនយោបាយជាតិស្តីពីសំណងសមរម្យ និងយុត្តិធម៌នៅឡើយ។

**បញ្ហាប្រឈមសម្រាប់រាជធានី ទីក្រុង និងទីប្រជុំជន៖**

- ការគាំទ្រក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រនៅតាមសហគមន៍សំណង់បណ្តោះអាសន្ន ឬសំណង់មិនរៀបរយនៅ

មានកម្រិត និងពុំទាន់ទូលំទូលាយនៅឡើយ

- ការគ្រប់គ្រងសំណល់រឹងរាវ និងបរិស្ថានក្នុងរាជធានី ទីក្រុង ទីប្រជុំជន និងសហគមន៍ត្រូវកែលម្អជាច្រើនចំណុចទៀត (សេវាដឹកជញ្ជូនសំរាម ឥរិយាបថរបស់ប្រជាពលរដ្ឋក្នុងការវិចខ្ចប់ និងការទទួលបានសេវាសុខភាពសម្រាប់ប្រជាជនក្រីក្រ។ល។)
- មានការបំពុលខ្យល់និងសំឡេងដោយមធ្យោបាយយានយន្តចាស់ៗនិងការកកស្ទះចរាចរណ៍ដែលធ្វើឱ្យខាតបង់ពេលវេលា ថវិកា និងបង្ករឱ្យគ្រោះថ្នាក់ផ្សេងៗដល់ប្រជាជន និងសង្គម
- មិនទាន់មានលំហសាធារណៈគ្រាប់គ្រាន់សម្រាប់សហគមន៍ និងសាធារណជន ពិសេសការយកផ្លូវថ្នល់ធ្វើជាចំណតរថយន្ត ធ្វើផ្សារលក់ដូរ និងប្រកាន់ខ្ជាប់ជាកម្មសិទ្ធិឯកជនក្នុងការប្រើប្រាស់ទីទាំងនោះ
- ពុំទាន់មានលំនៅឋានសង្គមសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប មធ្យម និងក្រុមងាយរងគ្រោះ
- គោលនយោបាយជាតិនានាត្រូវបានអនុវត្តមិនទាន់គ្រប់ជ្រុងជ្រោយ ជាពិសេសសម្រាប់សហគមន៍សំណង់បណ្ដោះអាសន្ន
- ការរៀបចំប្លង់គោលរាជធានីភ្នំពេញនៅមានភាពស្រពិចស្រពិលក្នុងការអនុវត្ត និងពុំបានផ្សព្វផ្សាយជាសាធារណៈ
- ទីក្រុង និងទីប្រជុំជនមួយចំនួនពុំទាន់មានប្លង់គោលប្រើប្រាស់ដីនៅឡើយដែលជាកត្តានាំឱ្យជួបនូវបញ្ហានៅពេលអនាគត និងរត់មិនទាន់ការរីករាលនៃនគរូបនីយកម្ម
- ការទទួលបាននូវការសិក្សាអប់រំដោយពុំបង់ថ្លៃមិនទាន់បានលាតសន្ធឹងវិសាសភាពគ្រប់គ្រាន់ដល់សហគមន៍ក្រីក្រនៅឡើយ
- កង្វះខាតថវិកានិងមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសាងសង់លំនៅឋានឱ្យបានសមរម្យដោយប្រឈមនឹងបំណុល
- មិនមានដីបម្រុងសម្រាប់សាងសង់លំនៅឋានសង្គមសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប
- ពុំទាន់ឃើញមានការលើកទឹកចិត្តសម្រាប់អ្នកសកម្មក្នុងការចូលរួមអភិវឌ្ឍសង្គម
- ការទទួលបាននូវប្លង់កម្មសិទ្ធិសម្រាប់សហគមន៍រស់នៅក្នុងតំបន់សំណង់បណ្ដោះអាសន្ននៅមានកម្រិត
- ពុំទាន់មានការចូលរួមយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋក្នុងការអភិវឌ្ឍទីក្រុងដោយតម្លាភាពនៅតាមមូលដ្ឋានដែលអភិវឌ្ឍ។ល។

### សំណូមពរសម្រាប់ដំណោះស្រាយបន្ត÷

- បន្តការងារដោះស្រាយសំណង់បណ្ដោះអាសន្ននិងបង្ករលទ្ធភាពឱ្យប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបនិងមធ្យមបានរស់នៅក្នុងលំនៅឋានសមរម្យដោយមានផែនការតាមជំហានៗច្បាស់លាស់ពី ១ ឆ្នាំទៅ១ ឆ្នាំដោះស្រាយបញ្ចប់ដោយមានការសហការជាមួយដៃគូអភិវឌ្ឍន៍នានា
- ផ្ដល់នូវភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចទទួលបាននូវព័ត៌មានពិតប្រាកដ និងត្រឹមត្រូវដើម្បីបានចូលរួមក្នុងការអភិវឌ្ឍទីក្រុង
- បង្កើន និងបង្កើតលំហសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់វ័យឱ្យទទួលបានការប្រើប្រាស់ក្នុងសហគមន៍
- គួរមានប្លង់គោលប្រើប្រាស់ដីសម្រាប់រាជធានី គ្រប់ទីក្រុង និងគ្រប់ទីប្រជុំជនទូទាំងប្រទេស

- គួរមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់ឱ្យបានគ្រប់ជំហានក្នុងការសម្រេចចិត្តសម្រាប់ការអភិវឌ្ឍទីក្រុង
- គួរមានគោលនយោបាយរួមសម្រាប់ការអភិវឌ្ឍរាជធានី ទីក្រុង និងទីប្រជុំជនដែលអាចអនុវត្តបានគ្រប់វិស័យ
- គួរមានបម្រុងដីសម្រាប់សាងសង់លំនៅឋានសង្គមមុននឹងអភិវឌ្ឍទីក្រុង
- គួរគិតពីការគ្រប់គ្រងគ្រោះមហន្តរាយដោយធម្មជាតិនិងមនុស្សមុននឹងអភិវឌ្ឍទីក្រុង
- គួរបង្កើនការគ្រប់គ្រងសំណល់រឹងរាវដែលបង្ករពីរោងចក្រ សហគ្រាស និងប្រជាពលរដ្ឋទូទៅ
- គួរយកចិត្តទុកដាក់និងលើកទឹកចិត្តក្នុងការប្រើប្រាស់មធ្យោបាយសាធារណៈដោយមានគុណវិស័យនិងបរិមាណវិស័យ
- គួរមានការរៀបចំផ្លូវសាធារណៈសម្រាប់ការប្រើប្រាស់សម្រាប់ទាំងអស់គ្នា (ថ្មើរជើង និងជិះកង់)
- គួររៀបចំឱ្យមានចំណតសាធារណៈអាចប្រើប្រាស់បានទាំងអស់គ្នា
- គួររក្សានូវអត្តសញ្ញាណ និងប្រវត្តិសាស្ត្រនៃទីតាំងតំបន់ដែលនឹងរៀបចំទៅជាទីក្រុងថ្មី និងទីតាំងអភិរក្សក្នុងគោលបំណងទេសចរណ៍
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល យល់ដឹងពីច្បាប់ គោលនយោបាយ និងការអនុវត្តឱ្យមានប្រសិទ្ធភាពទាក់ទងនឹងគុណភាពបរិស្ថាន ការប្រើប្រាស់រថយន្ត ការដឹកជញ្ជូន និងការទទួលបានសេវានិងធនធានស្មើភាពគ្នា។

**បញ្ជីឈ្មោះអ្នកចូលរួម៖**

| ល.រ. | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | Lors Sren | CMHPM | STT |
| ២ | Kensuke Matsueda | Programme Officer | UN-Habitat |
| ៣ | Lee Forsytht | USAID D6 | USAID |
| ៤ | Dear Stephania | Student | RUFA |
| ៥ | Suot Lyha | Student | RUFA |
| ៦ | Piseth Sensamras | Consultant | UN-Habitat |
| ៧ | Sandrine Capelle Manuel | Multi Country Office Director | UNOPS |
| ៨ | Kou Sina | Program Manager | UPWD |
| ៩ | Shunsake Miyacake | Director | ADK |
| ១០ | Si Qi Wan | Technical Officer | UNRCO |
| ១១ | Lars Stordal | UN-Habitat | UN-Habitat |
| ១២ | Bun Vanna | Director | CCHSR/NGOF |
| ១៣ | Duong Monirith | Student | PUC |
| ១៤ | Neren Panhavatey | Student | Paragon IU |
| ១៥ | Lara Moragrega | Marketing+PA | ULS |
| ១៦ | Laxman Percera | Huma Settlement Officer | UN-Habitat |

| | | | |
|---|---|---|---|
| ១៧ | Mihee Joo | KMCO | UNOPS |
| ១៨ | Chea Sophearith | CST | CRC.Cambodia |
| ១៩ | Meas Kimseng | UN-Habitat | UN-Habitat |
| ២០ | Sok Vanna | Program Manager | UN-Habitat |
| ២១ | Corbett | | Urban Living Solution |
| ២២ | Leap Dam | Project Coordinator | UN-Habitat |
| ២៣ | Okubo Kaori | Representative | JICA |
| ២៤ | Vithika Sophon | Student | Paragon IU |
| ២៥ | Kristin PARCO | Chief of Mission | IOM |
| ២៦ | Lay Sokheng | PCS | GMAC |
| ២៧ | An Phalla | Student | PUC |
| ២៨ | Thai Sreylin | Student | |
| ២៩ | Yuk Sothirith | GM | Worldbridge Homes |
| ៣០ | Seng Panha | Young Research Fellow | Future Forum |
| ៣១ | Karolien Casaer | Representative | GGGI |
| ៣២ | Phanha Ha | Student | Paragon University |
| ៣៣ | Chanthida Dum | NPO | IOM |
| ៣៤ | Olivia Hough | MD | Impact Hub PP |

## ឧបសម្ព័ន្ធទី ៤: ព្រឹត្តិការណ៍កសាងបណ្តាញកម្រិតខ្ពស់

### កិច្ចពិភាក្សាអំពីអនាគតនៃទីក្រុងអាស៊ីនិងប៉ាស៊ីហ្វិក

អមជាមួយនឹងវេទិកានេះ ក៏មានការប្រកាសផ្សព្វផ្សាយរបាយការណ៍ស្តីពីអនាគតទីក្រុងនៅអាស៊ីប៉ាស៊ីហ្វិកឆ្នាំ ២០១៩ ក្នុងព្រឹត្តិការណ៍ចងក្រងបណ្តាញកម្រិតខ្ពស់។

នៅឆ្នាំ ២០៣០ ឆ្នាំ ២០៥០ និងឆ្នាំ ២១០០ ទីក្រុងនឹងខុសប្លែកស្រឡះពីទីក្រុងនាពេលបច្ចុប្បន្ន។ ទីក្រុងទាំងនេះនឹងក្លាយជាទីក្រុងដែលមានការផ្លាស់ប្តូរទាំងសមាសភាពប្រជាសាស្ត្រ ការអនុវត្តបច្ចេកវិទ្យា និងបរិបទអេកូឡូស៊ីទូទៅ។ បញ្ហាប្រឈមក្នុងការកសាងទីក្រុងឱ្យមានចីរភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលមានការផ្លាស់ប្តូរនាពេលអនាគតគឺតម្រូវឱ្យមានការគិតគូរនិងការធ្វើការងារបែបថ្មី ព្រមទាំងការរៀបចំនូវគំនិតផ្តួចផ្តើម និងភាពជាដៃគូដែលមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះប្រភេទថ្មីៗ។ ការរៀនសួរសំណួរបែបថ្មីប្រសើរជាងមុន និងការកសាងអភិក្រមថ្មីៗដើម្បីដោះស្រាយបញ្ហាដែលធ្លាប់កើតមានកន្លងមកគឺជាតួនាទីដែលត្រូវបំពេញដោយភាគីពាក់ព័ន្ធនានាមិនថាវិស័យឯកជន ឬរដ្ឋនោះឡើយក្នុងគោលបំណងចង់ចូលរួមក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ។

របាយការណ៍ស្តីពីអនាគតទីក្រុងនៅអាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ ២០១៩ ត្រូវបានរៀបរៀងរួមគ្នាដោយ UNESCAP និង UN-Habitat ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប មជ្ឈមណ្ឌលសម្រាប់ទីក្រុងដែលសមស្របសម្រាប់ការរស់នៅរបស់សឹង្ហបុរី មូលនិធិ Rockefeller និង UNDP។ របាយការណ៍នេះស្នើឡើងនូវគោលនយោបាយសំខាន់ៗជាច្រើនដែលមានសារៈសំខាន់ដើម្បីធានាឱ្យទីក្រុងកាន់តែមានអនាគតកាន់តែប្រសើរដោយបែងចែកជាប្រធានបទជាអាទិភាពដូចតទៅ÷ នគរូបនីយកម្ម និងការរៀបចំដែនដី, ភាពធន់របស់ទីក្រុង, ទីក្រុងដែលឆ្លាតវៃនិងប្រកបដោយបរិយាបន្ន, និងហិរញ្ញប្បទានទីក្រុង។

### កម្មវិធី

សុន្ទរកថាស្វាគមន៍ដោយលោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា និង ឯកឧត្តម រីបូន កោម អគ្គលេខាធិការគណៈកម្មាធិការជាតិ UNESCAP ( ៥ នាទី)
វីដេអូបង្ហាញពីរបាយការណ៍ស្តីពីអនាគតទីក្រុងនៅអាស៊ី & ប៉ាស៊ីហ្វិក (២ នាទី)
បទបង្ហាញគន្លឹះស្តីពីរបាយការណ៍នេះដោយបណ្ឌិត Stefanos Fotiou ប្រធានផ្នែកបរិស្ថាន និងអភិវឌ្ឍន៍នៃ ESCAP (១០ នាទី)
បទអន្តរាគមន៍ដោយលោក Laxman Perera, មន្ត្រីលំនៅឋានមនុស្សជាតិ នៃការិយាល័យប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក កម្មវិធីលំនៅឋានមនុស្សជាតិរបស់អង្គការសហប្រជាជាតិ និងលោក Nick Beresford តំណាងអង្គការ UNDP ប្រចាំប្រទេសកម្ពុជា (១៥ នាទី)
សំណួរ ចម្លើយ និងពិធីជប់លៀងដើម្បីកសាងបណ្តាញជាមួយគ្នា




សូមដោនឡូតរបាយការណ៍
នៅទីនេះ÷

http://bit.ly/FoAPC2019

Photographs by:
Nhut - stock.adobe.com (front page)
andrii_lutsyk - stock.adobe.com (p.ii & xii)
UNICEF Cambodia (p. iv, 2, 3, 4, 5, 6, 7, 8, 9, 10, 11, 12, 13, 14, 15, 16, 17)
allPhoto Bangkok on Unsplash (backpage)

